ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី១៩ លេខ៥៨ ត្រីមាសទី០៣ ឆ្នាំ២០១៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

២៩-០៧-២០១៩ -ព្រះរាជក្រម នស/រកម/០៧១៩/០១០ ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ៦៦៦៩

២~ព្រះរាជក្រឹត្យ

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៧៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ខុនយ៉ាង** (WANG, KUNYANG) ជនជាតិចិន សញ្ជាតិចិន ៦៧៣៦

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៧៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ វៃភីង** (SU WEIPING) ជនជាតិចិន សញ្ជាតិចិន ៦៧៣៧

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៧៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អ៊ូ ជីឡុង** (WU JULONG) ជនជាតិចិន សញ្ជាតិចិន ៦៧៣៨

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ឈីងមូ** (SU, QINGMU) ជនជាតិចិន សញ្ជាតិចិន ៦៧៣៩

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ជើពីន** (HUANG, ZEBIN) ជនជាតិចិន សញ្ជាតិចិន ៦៧៤០

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ឈាន** (CHEN QUAN) ជនជាតិចិន សញ្ជាតិចិន ៦៧៤១

១៩-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ជានតុង** (CHEN JIANDONG) ជនជាតិចិន សញ្ជាតិចិន ៦៧៤២

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឡាង យ៉ុង** (LANG YONG) ជនជាតិចិន សញ្ជាតិចិន ៦៧៤៣

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្វាន សាយជូន** (FAN, SAIJUN) ជនជាតិចិន សញ្ជាតិចិន ៦៧៤៤

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ស៊ីនហួរ** (LIU, XINHUA) ជនជាតិចិន សញ្ជាតិចិន ៦៧៤៥

២០-០៧-២០១៩ -ព្រះរាជក្រឹត្យ នស/រកត/០៧១៩/១០៨៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ឺ ភួយតាយ** (YU PUI TAI) ជនជាតិចិន សញ្ជាតិចិន ៦៧៤៦

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០២-០៨-២០១៩ -អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពី ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ៦៧៤៧

១២-០៦-២០១៩ -អនុក្រឹត្យលេខ ៨០៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៥៨

១២-០៦-២០១៩ -អនុក្រឹត្យលេខ ៨១០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៧៦២

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៦៧៦៦

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៦៧៧១

១៧-០៦-២០១៩ -អនុក្រឹត្យលេខ ៨១៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧៧៥

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៨-០២-២០១៩ -ប្រកាសអន្តរក្រសួងលេខ ២២៣ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៩ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៦៧៧៦

០១-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ២២៨ សហវ.ហក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទានប្រចាំនៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៦៧៨០

០៤-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ២៣១ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក (គ.ស.ច.គ) នៃក្រសួងមហាផ្ទៃ ៦៧៨៣

០៤-០៣-២០១៩ -ប្រកាសអន្តរក្រសួងលេខ ២៣២ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ២០១៩ របស់អង្គភាពថវិកាទី១ និងទី២ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរ-ស៊ីវិល ៦៧៨៧

ព្រះរាជក្រម

នស/រកម/០៧១៩/០១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្ដីពី

ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃ កិច្ចព្រមព្រៀងស្ដីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និង លុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

មាត្រា១.-

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងស្ដីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលបានអនុម័តដោយសន្និសីទអង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅរដ្ឋធានីរ៉ូម នៃសាធារណរដ្ឋអ៊ីតាលី ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

មាត្រា៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

នស/រកម.១៩០៧.១១៤០

ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ដលេខា
នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កិច្ចព្រមព្រៀង
ស្តីពី
វិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

កិច្ចព្រមព្រៀងស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

បុព្វកថា

ភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ៖

ដោយព្រួយបារម្ភយ៉ាងខ្លាំង អំពីការបន្តកើតឡើងនូវការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដែលបង្កគ្រោះថ្នាក់ដល់ផលស្តុក ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងជីវភាពរស់នៅរបស់អ្នកនេសាទស្របច្បាប់ និងការកើនឡើងនូវតម្រូវការសន្តិសុខស្បៀងនៅលើពិភពលោក

ដោយយល់ច្បាស់ អំពីតួនាទីរបស់រដ្ឋម្ចាស់កំពង់ផែក្នុងការអនុម័តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីជំរុញការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សរយៈពេលយូរនៃធនធានជលផលសមុទ្រ

ដោយទទួលស្គាល់ថា វិធានការប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត គឺជាការទទួលខុសត្រូវរបស់រដ្ឋម្ចាស់ទង់ជាតិ និងអនុវត្តយុត្តាធិការដែលមានទាំងអស់ឱ្យស្របទៅតាមច្បាប់អន្តរជាតិ រួមមានវិធានការរដ្ឋម្ចាស់កំពង់ផែ វិធានការរដ្ឋម្ចាស់ឆ្នេរ វិធានការទីផ្សារ និងវិធានការពាក់ព័ន្ធផ្សេងទៀត ដើម្បីធានាថាប្រជាជាតិទាំងនោះមិនគាំទ្រ ឬមិនពាក់ព័ន្ធការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ដោយទទួលស្គាល់ថា វិធានការរដ្ឋម្ចាស់កំពង់ផែផ្តល់មធ្យោបាយដ៏មានឥទ្ធិពល និងមានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត

ដោយយល់ដឹង ពីភាពចាំបាច់សម្រាប់បង្កើនកិច្ចសម្របសម្រួល ទាំងនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតតាមរយៈការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ

ដោយទទួលស្គាល់ ចំពោះការកើនឡើងយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាទំនាក់ទំនង ទិន្នន័យមូលដ្ឋានបណ្តាញការងារ និងកំណត់ត្រាជាសកល ដែលគាំទ្រដល់វិធានការរដ្ឋម្ចាស់កំពង់ផែ

ដោយទទួលស្គាល់ ពីភាពចាំបាច់សម្រាប់ជួយដល់ប្រទេសកំពុងអភិវឌ្ឍក្នុងការអនុម័ត និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ

ដោយកត់សម្គាល់ ពីការអំពាវនាវរបស់សហគមន៍អន្តរជាតិ តាមរយៈប្រព័ន្ធអង្គការសហប្រជាជាតិ រួមទាំងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងគណៈកម្មការជលផលនៃអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិហៅកាត់ថា "FAO" ដែលបង្កើតក្របខ័ណ្ឌច្បាប់ក្នុងកម្រិតស្តង់ដាអប្បបរមាជាផ្លូវការសម្រាប់វិធានការរដ្ឋម្ចាស់កំពង់ផែ ដោយផ្អែកលើផែនការសកម្មភាពអន្តរជាតិរបស់អង្គការស្បៀងនិងកសិកម្មនៃសហ

ប្រជាជាតិឆ្នាំ២០០១ ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងគម្រោងការគំរូនៃវិធានការរដ្ឋម្ចាស់កំពង់ផែសម្រាប់ប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០៥

ដោយចងចាំថា នៅក្នុងការអនុវត្តអធិបតេយ្យភាពលើកំពង់ផែដែលស្ថិតនៅក្នុងដែនសមុទ្ររបស់ខ្លួន រដ្ឋទាំងឡាយអាចអនុម័តនូវវិធានការដ៏ម៉ឺងម៉ាត់បន្ថែមទៀត ដោយយោងតាមច្បាប់អន្តរជាតិ

ដោយរំលឹកឡើងវិញ នូវបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រដែលបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ដែលហៅកាត់ថា "អនុសញ្ញា"

ដោយរំលឹកឡើងវិញ នូវកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិទាំងឡាយ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៥ កិច្ចព្រមព្រៀងស្តីពីការលើកកម្ពស់ការអនុវត្តវិធានការគ្រប់គ្រង និងអភិរក្សអន្តរជាតិដោយនាវានេសាទនៅក្នុងដែនសមុទ្រអន្តរជាតិ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងក្រមប្រតិបត្តិស្តីពីការនេសាទដោយទទួលខុសត្រូវរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ១៩៩៥

ដោយទទួលស្គាល់ នូវភាពចាំបាច់ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងអន្តរជាតិមួយនៅក្នុងក្របខ័ណ្ឌរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិដែលមានចែងនៅក្នុងមាត្រា១៤ នៃធម្មនុញ្ញរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

បានព្រមព្រៀងដូចខាងក្រោម៖

ផ្នែកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១
ការប្រើវាក្យស័ព្ទ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

(ក) **"វិធានការគ្រប់គ្រង និងអភិរក្ស"** សំដៅដល់វិធានការទាំងឡាយសម្រាប់គ្រប់គ្រង និងអភិរក្សធនធានសមុទ្រមានជីវិត ដែលបានអនុម័ត និងអនុវត្តស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់អន្តរជាតិទាំងឡាយ រួមទាំងបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុសញ្ញា

(ខ) **"ត្រី"** សំដៅដល់ធនធានជលផលសមុទ្រមានជីវិតគ្រប់ប្រភេទទាំងអស់ ទោះជាផលិតផលកែច្នៃ ឬមិនទាន់កែច្នៃក៏ដោយ

(គ) **"ការនេសាទ"** សំដៅដល់ការរុករក ការទាក់ទាញ ការស្វែងរក ការចាប់ ការទាញយក ឬការប្រមូលផលត្រី ឬសកម្មភាពណាមួយដែលគិតថាជាលទ្ធផលពីការទាក់ទាញ ការស្វែងរក ការចាប់ ការទាញយក ឬការប្រមូលផលត្រី

(ឃ) **"សកម្មភាពទាក់ទងនឹងការនេសាទ"** សំដៅដល់ប្រតិបត្តិការណាមួយក្នុងការគាំទ្រ ឬការរៀបចំសម្រាប់ការនេសាទ រួមមានការឡើងផលនេសាទ ការវេចខ្ចប់ ការកែច្នៃ ការផ្ទេរ ឬការដឹកជញ្ជូនផលត្រីដែលពីមុនមកមិនធ្លាប់បានចូលចតនៅកំពង់ផែមួយ ក៏ដូចជាការផ្តល់បុគ្គលិក ប្រេងឥន្ធនៈ ឧបករណ៍ និងការផ្គត់ផ្គង់ផ្សេងៗទៀតនៅក្នុងសមុទ្រ

(ង) **"ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត"** សំដៅលើសកម្មភាពដែលមានចែងក្នុងកថាខណ្ឌទី៣ នៃផែនការសកម្មភាពអន្តរជាតិស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដែលហៅកាត់ថា "IUU Fishing" របស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ២០០១

(ច) **"ភាគី"** សំដៅដល់រដ្ឋមួយ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់មួយដែលបានយល់ព្រមតាមកិច្ចព្រមព្រៀងនេះនៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន

(ឆ) **"កំពង់ផែ"** រួមបញ្ចូលទាំងចំណតក្នុងសមុទ្រក្រៅ និងឋបនាដ្ឋាន(សំណង់)ផ្សេងៗ សម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ ការកែច្នៃ ការចាក់ប្រេងឥន្ធនៈ ឬការផ្គត់ផ្គង់ផ្សេងៗទៀត

(ជ) **"អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់"** សំដៅលើអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់មួយដែលរដ្ឋជាសមាជិករបស់អង្គការនោះ បានផ្ទេរសមត្ថកិច្ចលើកិច្ចការដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ រួមទាំងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចជាផ្លូវការទាំងឡាយជំនួសឱ្យរដ្ឋជាសមាជិករបស់អង្គការនេះ សម្រាប់បញ្ហាទាំងអស់នោះ

(ឈ) **"អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់"** សំដៅដល់អង្គការជលផលអន្តររដ្ឋាភិបាលមួយ ឬការរៀបចំសមស្របមួយ ដែលមានសមត្ថកិច្ចក្នុងការបង្កើតវិធានការគ្រប់គ្រង និងអភិរក្សធនធានជលផល និង

(ញ) **"នាវា"** សំដៅដល់នាវាណាមួយ ឬកប៉ាល់ផ្សេងៗ ឬទូកប្រើសម្រាប់ ឬបំពាក់សម្ភារៈបរិក្ខារប្រើសម្រាប់ ឬក្នុងគោលបំណងប្រើប្រាស់សម្រាប់ ការនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទ។

មាត្រា ២
គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត តាមរយៈការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែឱ្យមានប្រសិទ្ធភាព និង

ដើម្បីធានាបាននូវការអភិរក្សយូរអង្វែង ការប្រើធនធានជលផលសមុទ្រ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រឱ្យមាននិរន្តរភាព។

មាត្រា ៣
ការអនុវត្ត

១. ភាគីនីមួយៗដែលជារដ្ឋម្ចាស់កំពង់ផែ ត្រូវអនុវត្តកិច្ចព្រមព្រៀងនេះ ចំពោះនាវាទាំងឡាយណាដែលពុំមានសិទ្ធិប្រើទង់ជាតិរបស់ភាគីនោះ ហើយកំពុងស្វែងរកការចូលចតនៅក្នុងកំពង់ផែរបស់រដ្ឋម្ចាស់កំពង់ផែនោះ ឬក៏កំពុងស្ថិតនៅក្នុងកំពង់ផែណាមួយរបស់ភាគីម្ចាស់កំពង់ផែនោះ លើកលែងតែ៖

(ក) នាវានៃប្រទេសជិតខាងដែលធ្វើនេសាទជាលក្ខណៈប្រពៃណីសម្រាប់ចិញ្ចឹមជីវិត ដែលរដ្ឋម្ចាស់កំពង់ផែ និងរដ្ឋម្ចាស់ទង់ជាតិសហការគ្នាដើម្បីធានាថា នាវាទាំងនេះមិនពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ទាំងនោះទេ និង

(ខ) នាវាដឹកជញ្ជូនទាំងឡាយដែលមិនបានដឹកជញ្ជូនត្រី ឬប្រសិនបើដឹកជញ្ជូនត្រីដែលធ្លាប់បានឡើងនៅកំពង់ផែពីមុន ដែលពុំមានការសង្ស័យណាមួយថានាវានោះពាក់ព័ន្ធការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។

២. ភាគីមួយដែលក្នុងនាមជារដ្ឋម្ចាស់កំពង់ផែ អាចសម្រេចចិត្តមិនអនុវត្តកិច្ចព្រមព្រៀងនេះ ចំពោះនាវាទាំងឡាយណាដែលត្រូវបានជួលផ្តាច់មុខដោយជនជាតិរបស់រដ្ឋនោះ សម្រាប់ការនេសាទនៅក្នុងតំបន់ស្ថិតក្រោមយុត្តាធិការជាតិរបស់ខ្លួន និងការប្រតិបត្តិការនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ នាវាទាំងនេះនឹងត្រូវបានចាត់វិធានការដោយរដ្ឋម្ចាស់កំពង់ផែ ដែលជាវិធានការមានប្រសិទ្ធភាពដូចគ្នា សម្រាប់អនុវត្តទៅលើនាវាទាំងឡាយដែលពុំមានសិទ្ធិប្រើទង់ជាតិនៃរដ្ឋម្ចាស់កំពង់ផែ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះការនេសាទក្នុងដែននេសាទសមុទ្រ ដែលកើតមាននូវការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា ១ ចំណុច(ង)នៃកិច្ចព្រមព្រៀងនេះ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់។

៤. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តដោយស្មើភាព តម្លាភាព និងមិនរើសអើង ស្របតាមច្បាប់អន្តរជាតិ។

៥. ដោយកិច្ចព្រមព្រៀងនេះ មានវិសាលភាពជាសកល និងអនុវត្តចំពោះកំពង់ផែទាំងអស់ ភាគីទាំងអស់ត្រូវលើកទឹកចិត្តដល់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តវិធានការឱ្យស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ រដ្ឋណាដែលមិនទាន់បានក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ ក៏អាចបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការអនុវត្តវិធានការឱ្យស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដែរ។

មាត្រា ៤
ទំនាក់ទំនងជាមួយច្បាប់ និងលិខិតុបករណ៍អន្តរជាតិដទៃទៀត

១. គ្មានបទប្បញ្ញត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះ បង្កព្យសនកម្មចំពោះសិទ្ធិ យុត្តាធិការ និងករណីកិច្ច របស់ភាគីទាំងឡាយដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ។ ជាពិសេសគ្មានបទប្បញ្ញាត្តិណាមួយក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដែលនាំឱ្យប៉ះពាល់ដល់៖

(ក) អធិបតេយ្យភាពរបស់ភាគីទាំងឡាយលើដែនទឹកខាងក្នុង តំបន់ប្រជុំកោះ និងសមុទ្រដែនដីរបស់រដ្ឋទាំងនោះ ឬសិទ្ធិអធិបតេយ្យភាពលើតំបន់ខ្ពង់រាបបាតសមុទ្រ និងនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋទាំងនោះ

(ខ) ការអនុវត្តដោយភាគីដែលមានអធិបតេយ្យភាពលើកំពង់ផែទាំងឡាយ នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋរបស់ពួកគេស្របតាមច្បាប់អន្តរជាតិ ដោយរួមមានទាំងសិទ្ធិបដិសេធមិនឱ្យនាវាចូលចតក៏ដូចជាវិធានការរដ្ឋម្ចាស់កំពង់ផែដ៏តឹងរ៉ឹងជាងអ្វីដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ដោយរួមនឹងវិធានការនានាដែលបានស្របអនុម័តតាមសេចក្តីសម្រេចនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ណាមួយ។

២. ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីមួយអាចមិនទទួលស្គាល់ ឬមិនអនុវត្តវិធានការ ឬសេចក្តីសម្រេចនៃអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ណាមួយ ដែលភាគីនោះមិនមែនជាសមាជិក។

៣. គ្មានករណីណាមួយដែលតម្រូវឱ្យភាគីមួយស្ថិតក្រោមកិច្ចព្រមព្រៀងនេះ មានឥទ្ធិពលទៅលើវិធានការ ឬសេចក្តីសម្រេចទាំងអស់របស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ណាមួយ ប្រសិនបើវិធានការ ឬសេចក្តីសម្រេចទាំងនោះ មិនទាន់បានអនុម័តតាមច្បាប់អន្តរជាតិ។

៤. កិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយ និងអនុវត្តស្របតាមច្បាប់អន្តរជាតិ រួមមានបទដ្ឋាន និងនិយាមអន្តរជាតិ ព្រមទាំងវិធានការទាំងឡាយ បង្កើតដោយអង្គការសមុទ្រអន្តរជាតិ និងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត។

៥. ភាគីទាំងអស់ ត្រូវបំពេញកាតព្វកិច្ច និងអនុលោមឱ្យបានពេញលេញតាមកិច្ចព្រមព្រៀងនេះ និងត្រូវអនុវត្តសិទ្ធិដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ដោយមិនបង្កឱ្យមានការរំលោភបំពានសិទ្ធិ។

មាត្រា ៥
សមាហរណកម្ម និងការសម្របសម្រួលថ្នាក់ជាតិ

ភាគីនីមួយៗ ត្រូវអនុវត្តកិច្ចការទៅតាមលទ្ធភាពដែលអាចធ្វើបានដូចខាងក្រោម៖

(ក) ធ្វើសមាហរណកម្ម ឬសម្របសម្រួលវិធានការរដ្ឋម្ចាស់កំពង់ផែដែលទាក់ទងនឹងជលផលជាមួយប្រព័ន្ធគ្រប់គ្រងទូលំទូលាយរបស់រដ្ឋម្ចាស់កំពង់ផែ

(ខ) ធ្វើសមាហរណកម្មវិធានការរដ្ឋម្ចាស់កំពង់ផែ ជាមួយវិធានការផ្សេងទៀត ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ដោយរួមបញ្ចូលនូវផែនការសកម្មភាពអន្តរជាតិ ស្តីពីការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាតរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិឆ្នាំ ២០០១ និង

(គ) ចាត់វិធានការផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នជាតិពាក់ព័ន្ធនានា និងសម្របសម្រួលសកម្មភាពជាមួយស្ថាប័នទាំងនោះក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

មាត្រា ៦
កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មាន

១. ដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាព និងតម្រូវការរក្សាការសម្ងាត់ឱ្យបានត្រឹមត្រូវ ភាគីទាំងអស់ត្រូវសហការ និងផ្លាស់ប្តូរព័ត៌មានជាមួយរដ្ឋពាក់ព័ន្ធ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ដោយរាប់បញ្ចូលនូវវិធានការដែលបានអនុម័តដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ទាំងនោះ ទាក់ទងនឹងគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២. ភាគីនីមួយៗ ត្រូវអនុវត្តវិធានការទាំងនេះឱ្យបានខ្លាំងក្លាតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីគាំទ្រដល់វិធានការគ្រប់គ្រង និងអភិរក្សដែលបានអនុម័តដោយរដ្ឋ និងអង្គការអន្តរជាតិពាក់ព័ន្ធនានា។

៣. ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធភាពស្របទៅតាមស្ថានភាពសមស្រប ភាគីទាំងអស់ត្រូវសហការគ្នាទាំងថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក តាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការផ្សេងៗទៀត។

ផ្នែកទី ២
ការចូលចតនៅកំពង់ផែ

មាត្រា ៧
ការកំណត់កំពង់ផែ

១. ភាគីនីមួយៗ ត្រូវកំណត់ និងផ្សព្វផ្សាយអំពីកំពង់ផែទាំងអស់ សម្រាប់ឱ្យនាវាអាចស្នើសុំចូលចតស្របតាមកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗ ត្រូវផ្តល់បញ្ជីឈ្មោះកំពង់ផែដែលបានកំណត់ទៅអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។

២. ភាគីនីមួយៗ ត្រូវធានាឱ្យអស់លទ្ធភាពថាគ្រប់កំពង់ផែដែលបានកំណត់ និងផ្សព្វផ្សាយដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើអធិការកិច្ចតាមកិច្ចព្រមព្រៀងនេះ។

មាត្រា ៨
សំណើសុំមុនការចូលចតកំពង់ផែ

១. ភាគីនីមួយៗ ត្រូវតម្រូវឱ្យមានព័ត៌មានក្នុងកម្រិតស្តង់ដាអប្បបរមាមួយដូចមានចែងនៅក្នុងឧបសម្ព័ន្ធ "ក" ដែលត្រូវតែផ្តល់ឱ្យបានមុនពេលអនុញ្ញាតឱ្យនាវាចូលចតក្នុងកំពង់ផែរបស់ខ្លួន។

២. ភាគីនីមួយៗ ត្រូវតម្រូវឱ្យមានព័ត៌មានតាមកថាខណ្ឌទី១ នៃមាត្រានេះ ដោយត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យរដ្ឋម្ចាស់កំពង់ផែ មានពេលគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យព័ត៌មានទាំងនោះ។

មាត្រា ៩
ការអនុញ្ញាត ឬការបដិសេធចូលចតនៅកំពង់ផែ

១. បន្ទាប់ពីបានទទួលព័ត៌មានពាក់ព័ន្ធតាមតម្រូវការដូចមានចែងក្នុងមាត្រា៨ ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលអាចជាតម្រូវការសម្រាប់កំណត់ថា តើនាវាដែលកំពុងស្នើសុំចូលចតនៅក្នុងកំពង់ផែនោះ មានពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ដែរឬទេ ភាគីម្ចាស់កំពង់ផែនោះត្រូវសម្រេចចិត្តថាតើគួរអនុញ្ញាត ឬបដិសេធការចូលចតនៃនាវានោះ ហើយត្រូវជូនដំណឹងពីសេចក្តីសម្រេចនេះទៅកាន់នាវា ឬតំណាងរបស់នាវានោះ។

២. ក្នុងករណីអនុញ្ញាតឱ្យនាវាចូលចត មេបញ្ជាការនាវា ឬតំណាងនាវា ត្រូវបង្ហាញលិខិតអនុញ្ញាតសម្រាប់ការចូលចតដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ នៃភាគីម្ចាស់កំពង់ផែអំឡុងពេលនាវាមកដល់កំពង់ផែ។

៣. ក្នុងករណីបដិសេធការចូលចត ភាគីនីមួយៗ ត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះទៅកាន់រដ្ឋម្ចាស់ទង់ជាតិនៃនាវា រដ្ឋមានដែនសមុទ្រពាក់ព័ន្ធ អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការអន្តរជាតិផ្សេងៗទៀត តាមលទ្ធភាពដែលអាចធ្វើបាន។

៤. ដោយគ្មានព្យសនកម្មពីកថាខណ្ឌទី១ នៃមាត្រានេះ នៅពេលភាគីមួយមានភស្តុតាងគ្រប់គ្រាន់បង្ហាញថានាវាដែលកំពុងសុំចូលចតនៅកំពង់ផែនោះ ធ្លាប់ពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ជាពិសេសនៅពេលឃើញឈ្មោះនាវានោះស្ថិតក្នុងបញ្ជីនាវាពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ដែលបានកំណត់ដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ស្របតាមវិធាន និងនីតិវិធីនៃអង្គការនោះ និងដោយអនុលោមតាមច្បាប់អន្តរជាតិ ភាគីម្ចាស់កំពង់ផែ ត្រូវបដិសេធការចូលចតនៃនាវានោះនៅកំពង់ផែរបស់ខ្លួន ស្របតាមកថាខណ្ឌទី២ និងទី៣ នៃមាត្រា ៤។

៥. ទោះបីជាមានចែងក្នុងកថាខណ្ឌទី៣ និងទី៤ នៃមាត្រានេះក៏ដោយ ភាគីម្ចាស់កំពង់ផែក៏អាចអនុញ្ញាតឱ្យនាវាមួយចូលចតកំពង់ផែរបស់ខ្លួនបាន ដោយយោងលើកថាខណ្ឌដោយឡែក ក្នុងគោល

បំណងធ្វើអធិការកិច្ចនាវា និងអនុវត្តសកម្មភាពសមស្របផ្សេងទៀតដោយអនុលោមទៅតាមច្បាប់អន្តរជាតិ ដែលមានប្រសិទ្ធភាពស្មើនឹងការបដិសេធការចូលចតក្នុងកំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត និងសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់។

៦. យោងតាមកថាខណ្ឌទី៤ ឬទី៥ នៃមាត្រានេះ ភាគីម្ចាស់កំពង់ផែ ត្រូវបដិសេធការប្រើកំពង់ផែរបស់នាវាមួយក្នុងការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ ការកែច្នៃត្រី និងការប្រើសេវាកម្មកំពង់ផែផ្សេងទៀតមានជាអាទិ៍ ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអ៊ូជួសជុល។ ក្នុងកថាខណ្ឌទី២ និងទី៣ នៃមាត្រា១១ អាចអនុវត្តចំពោះករណីទាំងអស់ខាងលើ។ ការបដិសេធនៃការប្រើកំពង់ផែទាំងនេះ ត្រូវអនុវត្តដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។

មាត្រា ១០
ករណីប្រធានសក្តិ ឬគ្រោះថ្នាក់

អនុលោមតាមច្បាប់អន្តរជាតិ កិច្ចព្រមព្រៀងនេះ ពុំមានអ្វីប៉ះពាល់ដល់ការចូលចតនៃនាវានៅកំពង់ផែក្នុងករណីប្រធានសក្តិ ឬគ្រោះអាសន្នណាមួយ ឬក៏រារាំងរដ្ឋម្ចាស់កំពង់ផែ ក្នុងការអនុញ្ញាតឱ្យនាវាមួយដែលកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ ឬគ្រោះអាសន្នចូលចតក្នុងកំពង់ផែ ដើម្បីជួយសង្គ្រោះមនុស្ស ឬនាវា ឬយន្តហោះ។

ផ្នែកទី ៣
ការប្រើកំពង់ផែ

មាត្រា ១១
ការប្រើកំពង់ផែ

១. នៅពេលនាវាមួយបានចូលកំពង់ផែណាមួយ ដើម្បីប្រើកំពង់ផែសម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ និងការកែច្នៃត្រី ដែលពីមុនពុំធ្លាប់បានចូលចត និងសម្រាប់សេវាកម្មកំពង់ផែផ្សេងៗទៀតមានជាអាទិ៍ ការចាក់ប្រេងឥន្ធនៈ ការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអ៊ូជួសជុល ភាគីរដ្ឋម្ចាស់កំពង់ផែ ត្រូវតែបដិសេធការចូលចតនេះ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានរបស់ខ្លួន និងឱ្យស្របតាមច្បាប់អន្តរជាតិ រួមទាំងកិច្ចព្រមព្រៀងនេះ ក្នុងករណីដែល៖

(ក) ភាគីម្ចាស់កំពង់ផែរកឃើញថា នាវានោះមានលិខិតអនុញ្ញាតមិនមានសុពលភាពត្រឹមត្រូវ និងមិនអនុវត្តតាមការអនុញ្ញាតឱ្យធ្វើនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដទៃទៀតដែលតម្រូវដោយរដ្ឋម្ចាស់ទង់ជាតិ

(ខ) ភាគីម្ចាស់កំពង់ផែរកឃើញថា នាវានោះមានលិខិតអនុញ្ញាតមិនមានសុពលភាពត្រឹមត្រូវ និងមិនអនុវត្តតាមការអនុញ្ញាតឱ្យធ្វើនេសាទ ឬសកម្មភាពពាក់ព័ន្ធនឹងការនេសាទដទៃទៀតនៅតំបន់ក្រោមយុត្តាធិការជាតិដែលតម្រូវដោយរដ្ឋម្ចាស់ឆ្នេរ

(គ) ភាគីម្ចាស់កំពង់ផែទទួលបានភស្តុតាងច្បាស់លាស់ថា ផលនេសាទនៅលើនាវាដែលបានពីការនេសាទល្មើសច្បាប់នៅក្នុងតំបន់ដែលស្ថិតក្រោមយុត្តាធិការជាតិនៃរដ្ឋម្ចាស់ឆ្នេរ

(ឃ) រដ្ឋម្ចាស់ទង់ជាតិមិនបានឆ្លើយតបទាន់ពេលវេលាលើសំណើរបស់រដ្ឋម្ចាស់កំពង់ផែ អំពីផលនេសាទនៅលើនាវាថា ត្រីដែលនេសាទបានមានលក្ខណៈត្រឹមត្រូវស្របតាមតម្រូវការបទដ្ឋានគតិយុត្តិរបស់អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី២ និងទី៣នៃមាត្រា ៤

(ង) ភាគីម្ចាស់កំពង់ផែមានមូលហេតុត្រឹមត្រូវដែលអាចជឿជាក់បានថា នាវានោះអាចពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ រួមទាំងប្រភេទនាវាដែលមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៩ លុះត្រាតែនាវានោះ អាចបញ្ជាក់ថា៖

(i) ជានាវាដែលបានធ្វើសកម្មភាពស្របតាមវិធានការគ្រប់គ្រងនិងអភិរក្សដែលពាក់ព័ន្ធ ឬ

(ii) ក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិក ផ្គត់ផ្គង់ប្រេងឥន្ទនៈ ឧបករណ៍នេសាទ និងការផ្គត់ផ្គង់ដទៃទៀតនៅលើសមុទ្រ។ ចំពោះនាវាដែលមិនទទួលបាននូវការផ្គត់ផ្គង់ក្នុងខណៈពេលនោះ គឺជាប្រភេទនាវាដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៩។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះក៏ដោយ ភាគីម្ចាស់កំពង់ផែអាចអនុញ្ញាតការចូលចតនៃនាវាដែលត្រូវការប្រើសេវាកម្មកំពង់ផែ ក្នុងករណីដូចខាងក្រោម៖

(ក) មានការចាំបាច់ទាក់ទងទៅនឹងសុវត្ថិភាព ឬសុខភាពរបស់នាវិក ឬសុវត្ថិភាពរបស់នាវានៅពេលមានការផ្តល់ភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ពីភាពចាំបាច់ទាំងនេះ ឬ

(ខ) នៅពេលនាវាដែលរងនូវការប៉ះទង្គិចបែកបាក់ ដែលត្រូវការចូលចតជាបន្ទាន់។

៣. បើភាគីម្ចាស់កំពង់ផែបានបដិសេធនូវការប្រើកំពង់ផែរបស់ខ្លួនស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ ភាគីម្ចាស់កំពង់ផែត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនទៅដល់រដ្ឋម្ចាស់ទង់ជាតិ បណ្តារដ្ឋម្ចាស់ឆ្នេរ បណ្តាអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងបណ្តាអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងៗទៀត។

៤. ភាគីម្ចាស់កំពង់ផែ ត្រូវលុបចោលនូវការបដិសេធលើការប្រើកំពង់ផែ ស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ ចំពោះនាវាដែលមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អ្វីដែលបានបដិសេធនេះមានលក្ខណៈមិនគ្រប់គ្រាន់ ឬមានការភាន់ច្រឡំ ឬមូលហេតុទាំងអស់នោះ លែងមានសុពលភាព។

៥. បើភាគីម្ចាស់កំពង់ផែបានលុបចោលនូវការបដិសេធរបស់ខ្លួន ស្របតាមកថាខណ្ឌទី៤ នៃមាត្រានេះ ត្រូវជូនដំណឹងជាបន្ទាន់អំពីសេចក្តីប្រកាសនោះទៅដល់បណ្តាប្រទេស និងអង្គការពាក់ព័ន្ធ ស្របតាមកថាខណ្ឌទី៣ នៃមាត្រានេះ។

ផ្នែកទី ៤
អធិការកិច្ច និងសកម្មភាពតាមដាន

មាត្រា ១២
កម្រិត និងអាទិភាពសម្រាប់អធិការកិច្ច

១. ភាគីនីមួយៗ ត្រូវធ្វើអធិការកិច្ចឱ្យបានទៀងទាត់នូវចំនួននាវាដែលចូលមកកំពង់ផែរបស់ខ្លួនជារៀងរាល់ឆ្នាំ ដើម្បីសម្រេចតាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២. ភាគីទាំងអស់ ត្រូវស្វែងរកការឯកភាពក្នុងកម្រិតអប្បបរមាសម្រាប់ការធ្វើអធិការកិច្ចនាវាឱ្យបានត្រឹមត្រូវ តាមរយៈអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ឬអង្គការផ្សេងៗទៀត។

៣. ក្នុងការកំណត់នាវាដែលត្រូវធ្វើអធិការកិច្ច ភាគីម្ចាស់កំពង់ផែត្រូវផ្តល់អាទិភាពចំពោះ៖

(ក) នាវាដែលធ្លាប់ត្រូវបានបដិសេធមិនឱ្យចូលចតនៅកំពង់ផែ ឬមិនឱ្យប្រើកំពង់ផែ ដោយយោងតាមកិច្ចព្រមព្រៀងនេះ

(ខ) មានការស្នើសុំឱ្យធ្វើអធិការកិច្ចពីភាគីរដ្ឋ ឬអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធផ្សេងទៀត ដោយមានភស្តុតាងបញ្ជាក់ថា នាវានេះមានការពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ និង

(គ) នាវាផ្សេងទៀតដែលមានការសង្ស័យខ្លាំងថា ជានាវាមានការពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់។

មាត្រា ១៣
ដំណើរការនៃការធ្វើអធិការកិច្ច

១. ភាគីនីមួយៗ ត្រូវធានាថា មន្ត្រីអធិការកិច្ចរបស់ខ្លួនអនុវត្តមុខងារ និងតួនាទីដូចមានចែងក្នុងឧបសម្ព័ន្ធ"ខ"ឱ្យបានក្នុងកម្រិតស្តង់ដាអប្បបរមា។

២. ភាគីនីមួយៗ ត្រូវធ្វើអធិការកិច្ចនៅកំពង់ផែរបស់ខ្លួនដូចខាងក្រោម៖

(ក) ធានាថា ការធ្វើអធិការកិច្ចបានប្រព្រឹត្តទៅដោយមន្ត្រីអធិការកិច្ចដែលមានសមត្ថភាព និងមានសិទ្ធិអំណាចគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនេះ ដូចមានចែងក្នុងមាត្រា១៧

(ខ) ធានាថា នៅមុនពេលធ្វើអធិការកិច្ច មន្ត្រីអធិការកិច្ចត្រូវបង្ហាញឯកសារសម្គាល់ខ្លួនដែលបញ្ជាក់ថាជាមន្ត្រីអធិការកិច្ចដល់មេបញ្ជាការនាវា

(គ) ធានាថា មន្ត្រីអធិការកិច្ចត្រួតពិនិត្យគ្រប់ទីកន្លែងពាក់ព័ន្ធទាំងអស់នៅលើនាវា ផលនេសាទលើនាវា ឧបករណ៍នេសាទ និងឧបករណ៍ផ្សេងៗទៀត សម្ភារៈបរិក្ខារ ឯកសារ ឬកំណត់ត្រានៅលើនាវាពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់ស្របទៅតាមវិធានការគ្រប់គ្រង និងការអភិរក្សដែលពាក់ព័ន្ធ

(ឃ) តម្រូវឱ្យមេបញ្ជាការនាវាផ្តល់កិច្ចសហការ និងព័ត៌មានចាំបាច់ទាំងអស់ដល់មន្ត្រីអធិការកិច្ច ហើយបង្ហាញឯកសារពាក់ព័ន្ធ ឬឯកសារថតចម្លង តាមតម្រូវការរបស់មន្ត្រីអធិការកិច្ច

(ង) ក្នុងករណីមានការសម្របសម្រួលល្អជាមួយរដ្ឋម្ចាស់ទង់ជាតិរបស់នាវា ត្រូវអញ្ជើញរដ្ឋម្ចាស់ទង់ជាតិនោះឱ្យចូលរួមក្នុងការធ្វើអធិការកិច្ច

(ច) ត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីជៀសវាងការពន្យារពេលក្នុងការធ្វើអធិការកិច្ចនាវា កាត់បន្ថយការរំខាន និងការខាតពេលវេលា រួមទាំងវត្តមានមន្ត្រីអធិការកិច្ចដែលមិនចាំបាច់នៅលើនាវា និងជៀសវាងនូវសកម្មភាពណាមួយដែលធ្វើឱ្យខូចគុណភាពផលនេសាទនៅលើនាវា

(ឆ) ត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីសម្របសម្រួល ទំនាក់ទំនងជាមួយមេបញ្ជាការនាវា ឬប្រធាននាវិក ដើម្បីឱ្យមន្ត្រីអធិការកិច្ចមានអ្នកបកប្រែចូលរួមការងារនៅកន្លែងដែលអាច និងចាំបាច់ទាំងអស់លើនាវា ក្នុងការធ្វើអធិការកិច្ច

(ជ) ធានាថា ការធ្វើអធិការកិច្ចទាំងអស់ត្រូវបានប្រព្រឹត្តទៅដោយលក្ខណៈត្រឹមត្រូវ តម្លាភាព និងមិនរើសអើង ហើយមិនត្រូវមានការបំពានណាមួយចំពោះនាវានោះ និង

(ឈ) មិនត្រូវរំខានដល់លទ្ធភាពនៃការទំនាក់ទំនងរបស់មេបញ្ជាការនាវាជាមួយអាជ្ញាធរ នៃរដ្ឋម្ចាស់ទង់ជាតិ ដោយយោងតាមច្បាប់អន្តរជាតិ។

មាត្រា ១៤
លទ្ធផលនៃការធ្វើអធិការកិច្ច

ភាគីនីមួយៗ ត្រូវធ្វើរបាយការណ៍ក្នុងកម្រិតស្តង់ដាអប្បបរមា ដោយរួមបញ្ចូលព័ត៌មានដូចមានចែងក្នុងឧបសម្ព័ន្ធ"គ" នៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការធ្វើអធិការកិច្ចម្តងៗ។

មាត្រា ១៥
ការបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ច

ភាគីនីមួយៗ ត្រូវបញ្ជូនលទ្ធផលនៃការធ្វើអធិការកិច្ចនាវាទៅរដ្ឋម្ចាស់ទង់ជាតិរបស់នាវានីមួយៗឱ្យមានលក្ខណៈត្រឹមត្រូវ ដោយផ្ញើទៅកាន់៖

(ក) ភាគី និងរដ្ឋពាក់ព័ន្ធរួមមាន៖

(i) រដ្ឋដែលមានភស្តុតាងតាមរយៈការធ្វើអធិការកិច្ចបង្ហាញថា នាវាធ្លាប់ពាក់ព័ន្ធនឹងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់នៅក្នុងដែនសមុទ្រដែលស្ថិតក្រោមយុត្តាធិការជាតិនៃរដ្ឋនោះ

(ii) រដ្ឋដែលមានមេបញ្ជាការនាវា មានសញ្ជាតិជាពលរដ្ឋនៃប្រទេសនោះ

(ខ) អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធនានា និង

(គ) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធផ្សេងទៀត។

មាត្រា ១៦
ការផ្លាស់ប្តូរព័ត៌មានតាមអេឡិចត្រូនិច

១. ដើម្បីសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗ ត្រូវបង្កើតយន្តការទំនាក់ទំនងដែលអនុញ្ញាតដល់ការផ្លាស់ប្តូរព័ត៌មានជាសារអេឡិចត្រូនិចដោយផ្ទាល់ តាមដែលអាចធ្វើទៅបាន ដោយស្ថិតក្នុងលក្ខខណ្ឌសម្ងាត់ដ៏សមស្រប។

២. តាមលទ្ធភាពដែលអាចធ្វើបាន និងលក្ខខណ្ឌសម្ងាត់សមស្រប ភាគីទាំងអស់ត្រូវសហការគ្នាដើម្បីបង្កើតយន្តការចែករំលែកព័ត៌មានមួយ ដែលអាចជាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិជាអ្នកសម្របសម្រួល ដោយភ្ជាប់ជាមួយនឹងការផ្តួចផ្តើមរបស់ពហុភាគី និងអន្តររដ្ឋាភិបាលពាក់ព័ន្ធផ្សេងៗ និងដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មាននៅក្នុងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនានាដែលមានស្រាប់ តាមកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗ ត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចដែលត្រូវដើរតួជាអ្នកទំនាក់ទំនង សម្រាប់ការផ្លាស់ប្តូរព័ត៌មានស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗ ត្រូវជូនដំណឹងដល់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិនូវសមត្ថកិច្ចដែលត្រូវបានតែងតាំងនោះ។

៤. ភាគីនីមួយៗ ត្រូវគ្រប់គ្រងព័ត៌មានដែលនឹងត្រូវបញ្ជូនតាមរយៈយន្តការណាមួយដែលបានបង្កើតឡើងស្របតាមកថាខណ្ឌទី១ នៃមាត្រានេះឱ្យមានសង្គតិភាពជាមួយឧបសម្ព័ន្ធ"ឃ"។

៥. អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ត្រូវស្នើអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានទាក់ទងនឹងវិធានការ ឬសេចក្តីសម្រេចទាំងឡាយដែលបានអនុម័ត និងអនុវត្តពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ សម្រាប់ធ្វើសមាហរណកម្មរបស់ខ្លួន តាមដែលអាចធ្វើទៅបាន និងរក្សាការសម្ងាត់សមស្របក្នុងយន្តការចែករំលែកព័ត៌មានដូចមានចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រានេះ។

មាត្រា ១៧
ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ច

ភាគីនីមួយៗ ត្រូវធានាថាមន្ត្រីអធិការកិច្ចរបស់ខ្លួនទទួលបានការបង្ហាត់បង្រៀនត្រឹមត្រូវតាមគោលការណ៍ណែនាំស្តីពីការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចនៅក្នុងឧបសម្ព័ន្ធ"ង"។ ភាគីទាំងអស់ ត្រូវស្វែងរកកិច្ចសហការក្នុងការងារនេះ។

មាត្រា ១៨
វិធានការរដ្ឋម្ចាស់កំពង់ផែក្រោយការធ្វើអធិការកិច្ច

១. ក្រោយធ្វើអធិការកិច្ចរួច ភាគីដែលមានមូលហេតុច្បាស់លាស់អាចជឿជាក់បានថា នាវាណាមួយបានចូលរួមសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬធ្វើសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ ភាគីអធិការកិច្ចត្រូវ៖

(ក) ជូនដំណឹងជាបន្ទាន់ដល់រដ្ឋម្ចាស់ទង់ជាតិ និងរដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនានា អង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ និងអង្គការអន្តរជាតិនានា ព្រមទាំងរដ្ឋដែលមានមេបញ្ជាការនាវាមានសញ្ជាតិនៃរដ្ឋនោះ អំពីលទ្ធផលនៃការធ្វើអធិការកិច្ចនោះ និង

(ខ) បដិសេធនាវានោះមិនឱ្យប្រើកំពង់ផែរបស់ខ្លួនសម្រាប់ការឡើងផលនេសាទ ការផ្ទេរ ការវេចខ្ចប់ និងការកែច្នៃត្រីដែលមិនធ្លាប់បានចូលចតពីមុន និងប្រើសេវាកម្មកំពង់ផែផ្សេងទៀត រួមមានទាំងការចាក់ប្រេង និងការផ្គត់ផ្គង់សម្ភារៈបរិក្ខា ការថែទាំ និងការឡើងអ៊ូជួសជុល ប្រសិនបើវិធានការទាំងនេះមិនត្រូវបានអនុវត្តចំពោះនាវានោះស្របនឹងកិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលទាំងមាត្រា ៤ ផង។

២. ទោះបីជាមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះក្តី ភាគីនៃកិច្ចព្រមព្រៀងមិនត្រូវបដិសេធចំពោះនាវាដែលស្នើប្រើសេវាកម្មកំពង់ផែជាចាំបាច់បំផុតសម្រាប់សុវត្ថិភាព ឬសុខភាពរបស់នាវិក ឬសុវត្ថិភាពរបស់នាវាផ្ទាល់។

៣. គ្មានលក្ខខណ្ឌណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ រារាំងភាគីមួយមិនឱ្យចាត់វិធានការនានា ស្របតាមច្បាប់អន្តរជាតិ ក្នុងការបំពេញបន្ថែមទៅនឹងវិធានការដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រានេះ រួមទាំងវិធានការរដ្ឋម្ចាស់ទង់ជាតិរបស់នាវាដែលបានបញ្ជាក់ពីការស្នើសុំ ឬអ្វីដែលបាននឹងកំពុងអនុញ្ញាត ឬយល់ព្រម ។

មាត្រា ១៩
ព័ត៌មានឧបាស្រ័យនៅក្នុងរដ្ឋម្ចាស់កំពង់ផែ

១. ភាគីត្រូវរក្សាទុកនូវព័ត៌មានពាក់ព័ន្ធដែលអាចប្រើការបានជាសាធារណៈ និងផ្តល់ព័ត៌មានទាំងនោះទៅតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់នាវា ប្រតិបត្តិករនាវា ម្ចាស់ ឬតំណាងនាវាជាមួយនឹងការឧបាស្រ័យណាមួយដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួន ស្តីអំពីវិធានការរដ្ឋម្ចាស់កំពង់ផែដែលទទួលយកដោយភាគី អនុលោមតាមមាត្រា៩ មាត្រា១១ មាត្រា១៣ ឬមាត្រា១៨ រាប់បញ្ចូលទាំងព័ត៌មានដែលទាក់ទងនឹងសេវាសាធារណៈ ឬស្ថាប័នតុលាការដែលមានស្រាប់

ក៏ដូចជាព័ត៌មានថាតើមានសិទ្ធិស្វែងរកសំណងដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាតិរបស់ខ្លួន នៅក្នុងហេតុការណ៍នៃការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយការចោទប្រកាន់ណាមួយពីភាគីថាជាសកម្មភាពខុសច្បាប់។

២. ភាគីត្រូវជូនដំណឹងដល់រដ្ឋម្ចាស់ទង់ជាតិ ម្ចាស់នាវា ប្រតិបត្តិករនាវា មេបញ្ជាការ ឬតំណាងអំពីលទ្ធផលនៃឧបាស្រ័យទាំងនោះឱ្យបានសមស្រប។ ខណៈពេលដែលភាគីផ្សេងទៀត រដ្ឋ ឬអង្គការអន្តរជាតិត្រូវបានជូនដំណឹងពីសេចក្ដីសម្រេចពីមុន ដោយអនុលោមតាមមាត្រា៩ មាត្រា១១ មាត្រា១៣ ឬមាត្រា១៨ ភាគី ត្រូវជូនដំណឹងទៅពួកគេពីការផ្លាស់ប្ដូរណាមួយនៅក្នុងការសម្រេចរបស់ខ្លួន។

ផ្នែកទី ៥
តួនាទីរដ្ឋម្ចាស់ទង់ជាតិ

មាត្រា ២០
តួនាទីរដ្ឋម្ចាស់ទង់ជាតិ

១. ភាគីនីមួយៗ ត្រូវឱ្យនាវាប្រើទង់ជាតិរបស់ខ្លួន សហការជាមួយរដ្ឋម្ចាស់កំពង់ផែក្នុងការធ្វើអធិការកិច្ចដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

២. នៅពេលដែលភាគីមានមូលហេតុច្បាស់លាស់ដែលអាចជឿជាក់បានថា នាវាប្រើទង់ជាតិរបស់ខ្លួនបានចូលរួមប្រព្រឹត្តបទល្មើសនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ និងកំពុងស្វែងរកការចូលចតនៅរដ្ឋផ្សេងទៀត ភាគីត្រូវស្នើទៅរដ្ឋនោះ ដើម្បីធ្វើអធិការកិច្ចនាវា ឬចាត់វិធានការផ្សេងទៀតឱ្យបានសមស្របទៅនឹងកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗ ត្រូវលើកទឹកចិត្តឱ្យនាវាដែលប្រើទង់ជាតិរបស់ខ្លួនដើម្បីឡើងផលនេសាទ ផ្ទេរ វេចខ្ចប់ និងកែច្នៃត្រី និងប្រើសេវាកម្មកំពង់ផែផ្សេងទៀតនៅកំពង់ផែនៃរដ្ឋទាំងឡាយដែលកំពុងអនុវត្តវិធានការស្របតាមកិច្ចព្រមព្រៀងនេះ។ ភាគីទាំងឡាយត្រូវបានលើកទឹកចិត្តតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ឱ្យបង្កើតនីតិវិធីត្រឹមត្រូវ មានតម្លាភាព និងមិនរើសអើងក្នុងការ កំណត់អត្តសញ្ញាណរដ្ឋណាមួយដែលមិនអនុវត្តតាមឬមានលក្ខណៈមិនស្របនឹងកិច្ចព្រមព្រៀងនេះ។

៤. បន្ទាប់ពីបានទទួលរបាយការណ៍នៃការធ្វើអធិការកិច្ចពីរដ្ឋម្ចាស់កំពង់ផែ ដែលបង្ហាញពីមូលហេតុច្បាស់លាស់ដែលអាចជឿជាក់បានថា នាវាដែលប្រើទង់ជាតិរបស់ខ្លួនបានរួមចំណែកក្នុងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ រដ្ឋម្ចាស់ទង់ជាតិនោះត្រូវធ្វើការស៊ើបអង្កេតភ្លាម និងពេញលេញ និងយោងតាមភស្តុតាងគ្រប់គ្រាន់ដើម្បីចាត់វិធានការបង្ក្រាបដោយមិនបង្អែបង្អង់ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន។

៥. ភាគីនីមួយៗជារដ្ឋម្ចាស់ទង់ជាតិ ត្រូវរាយការណ៍ទៅភាគីផ្សេងៗ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋពាក់ព័ន្ធផ្សេងទៀត ព្រមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ ក៏ដូចជាអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អំពីសកម្មភាពខ្លួនដែលបានចាត់វិធានការទាក់ទងនឹងនាវាដែលប្រើទង់ជាតិរបស់ខ្លួន ដែលបានរកឃើញថា នាវានោះបានចូលរួមក្នុងសកម្មភាពនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ទាំងនោះ យោងតាមលទ្ធផលនៃការចាត់វិធានការពីរដ្ឋម្ចាស់កំពង់ផែដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

៦. ភាគីនីមួយៗ ត្រូវធានាថា វិធានការនានាដែលបានអនុវត្តចំពោះនាវាដែលប្រើទង់ជាតិរបស់ខ្លួនយ៉ាងហោចណាស់ក៏មានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលគាំទ្រដល់ការនេសាទខុសច្បាប់ដូចវិធានការដែលបានអនុវត្តលើនាវាទាំងនោះ ផ្អែកតាមកថាខណ្ឌទី១នៃមាត្រា ៣។

ផ្នែកទី ៦
តម្រូវការរដ្ឋកំពុងអភិវឌ្ឍ

មាត្រា ២១
តម្រូវការរដ្ឋកំពុងអភិវឌ្ឍ

១. ភាគីទាំងអស់ ត្រូវទទួលស្គាល់ពេញលេញនូវតម្រូវការពិសេសរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍទាក់ទងនឹងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែសមស្របនឹងកិច្ចព្រមព្រៀងនេះ។ ហេតុដូច្នេះ ភាគីត្រូវជួយដោយផ្ទាល់ ឬតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ភ្នាក់ងារឯកទេសផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ឬអង្គការ និងស្ថាប័នអន្តរជាតិសមស្របផ្សេងទៀត រួមទាំងអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ផងដើម្បីជួយដល់រដ្ឋកំពុងអភិវឌ្ឍ៖

(ក) បង្កើនលទ្ធភាពរបស់បណ្ដារដ្ឋ ជាពិសេសរដ្ឋដែលមានការអភិវឌ្ឍតិចតួច និងរដ្ឋដែលជាដីកោះតូចៗកំពុងអភិវឌ្ឍ ដើម្បីបង្កើនសមត្ថភាពសម្រាប់ការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែប្រកបដោយប្រសិទ្ធភាព

(ខ) សម្របសម្រួលដល់ការចូលរួមរបស់បណ្ដារដ្ឋទាំងនោះ ជាមួយអង្គការអន្តរជាតិនានាដែលជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ និង

(គ) សម្រួលដល់ការផ្ដល់ជំនួយបច្ចេកទេសក្នុងការពង្រឹងការអភិវឌ្ឍ និងការអនុវត្តវិធានការរដ្ឋម្ចាស់កំពង់ផែ ជាមួយយន្តការអន្តរជាតិពាក់ព័ន្ធនានា។

២. ភាគីទាំងឡាយត្រូវយកចិត្តទុកដាក់ទៅលើតម្រូវការពិសេសរបស់រដ្ឋម្ចាស់កំពង់ផែដែលកំពុងអភិវឌ្ឍជាពិសេសរដ្ឋអភិវឌ្ឍតិចតួច និងបណ្ដារដ្ឋដែលជាដីកោះតូចៗកំពុងអភិវឌ្ឍ ដើម្បីធានាថា បន្ទុកមិនសមាមាត្រមួយ ដែលកើតចេញពីការអនុវត្តកិច្ចព្រមព្រៀងនេះ មិនត្រូវបានផ្ទេរដោយផ្ទាល់ ឬដោយ

ប្រយោលទៅកាន់ពួកគេនោះទេ។ ក្នុងករណីការផ្ទេរបន្ទុកមិនស្មើគ្នាត្រូវបានបង្ហាញ ភាគីត្រូវសហការគ្នាជាមួយភាគី នៃរដ្ឋកំពុងអភិវឌ្ឍពាក់ព័ន្ធ ដើម្បីសម្រួលដល់ការអនុវត្តកាតព្វកិច្ចជាក់លាក់ ក្រោមកិច្ចព្រមព្រៀងនេះ។

៣. ភាគីត្រូវសិក្សាវាយតម្លៃទៅលើតម្រូវការពិសេសរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍដោយផ្ទាល់ ឬតាមរយៈអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះ។

៤. ភាគីត្រូវសហការគ្នាដើម្បីបង្កើតយន្តការផ្តល់មូលនិធិសមស្រប ដើម្បីជួយដល់រដ្ឋកំពុងអភិវឌ្ឍក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។ យន្តការទាំងនេះ ត្រូវសំដៅឆ្ពោះទៅកាន់កិច្ចការជាក់លាក់ដែលមានជាអាទិ៍ដូចខាងក្រោម៖

(ក) អភិវឌ្ឍន៍វិធានការរដ្ឋម្ចាស់កំពង់ផែជាតិ និងអន្តរជាតិ

(ខ) អភិវឌ្ឍន៍ និងបង្កើនសមត្ថភាពរួមបញ្ចូលទាំងការតាមដាន ត្រួតពិនិត្យ និងអង្កេត សម្រាប់ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងតំបន់ចំពោះអ្នកគ្រប់គ្រងកំពង់ផែ មន្ត្រីអធិការកិច្ច មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីច្បាប់នានា

(គ) សកម្មភាពតាមដាន ត្រួតពិនិត្យ អង្កេត និងការគោរពតាមច្បាប់ពាក់ព័ន្ធនឹងវិធានការរដ្ឋម្ចាស់កំពង់ផែ រួមទាំងការប្រើបច្ចេកវិទ្យា និងឧបករណ៍ផ្សេងៗ និង

(ឃ) ជួយដល់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍ ទាក់ទងនឹងការចំណាយពាក់ព័ន្ធលើកិច្ចដំណើរការណាមួយ ក្នុងការដោះស្រាយវិវាទដែលបណ្តាលមកពីសកម្មភាពនានាដែលពួកគេបានចាត់វិធានការសមស្របតាមកិច្ចព្រមព្រៀងនេះ។

៥. កិច្ចសហប្រតិបត្តិការជាមួយ និងក្នុងចំណោមភាគីនៃរដ្ឋកំពុងអភិវឌ្ឍទាំងឡាយសម្រាប់កំណត់គោលបំណងក្នុងមាត្រានេះ អាចរួមបញ្ចូលទាំងការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុតាមរយៈបណ្តាញទ្វេភាគី ពហុភាគី និងថ្នាក់តំបន់ រួមទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូងផង។

៦. ភាគីទាំងឡាយត្រូវបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីរាយការណ៍ជាទៀងទាត់តាមកាលកំណត់ និងផ្តល់អនុសាសន៍ដល់ភាគីនានា ស្តីពីការបង្កើតយន្តការផ្តល់មូលនិធិ រួមមានជាទម្រង់មួយសម្រាប់ការចូលរួមវិភាគទាន ការកំណត់ និងការកៀងគរមូលនិធិ ការរៀបចំលក្ខខណ្ឌ និងនីតិវិធី ដើម្បីណែនាំទៅលើការអនុវត្ត ព្រមទាំងវឌ្ឍនភាពនៃការអនុវត្តយន្តការផ្តល់មូលនិធិនេះ។ បន្ថែមលើការយកចិត្តទុកដាក់ដូចមានចែងក្នុងមាត្រានេះ ក្រុមការងារចំពោះកិច្ច ត្រូវពិចារណាទៅលើការងារមួយចំនួនទៀត ជាអាទិ៍ដូចខាងក្រោម៖

(ក) ការវាយតម្លៃតម្រូវការរបស់ភាគីនៃរដ្ឋកំពុងអភិវឌ្ឍ ជាពិសេសរដ្ឋអភិវឌ្ឍតិចតួច និងរដ្ឋកោះតូចៗកំពុងអភិវឌ្ឍ

(ខ) មានមូលនិធិ និងការផ្ដល់ទាន់ពេលវេលា

(គ) តម្លាភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងដំណើរការគ្រប់គ្រងពាក់ព័ន្ធនឹងការគៀងគរ និងការបែងចែកមូលនិធិ និង

(ឃ) គណនេយ្យភាពនៃអ្នកទទួលមូលនិធិ តាមបណ្ដាភាគីនៃរដ្ឋកំពុងអភិវឌ្ឍក្នុងការព្រមព្រៀងលើការប្រើមូលនិធិ។

ភាគីត្រូវពិចារណាទៅលើរបាយការណ៍ និងអនុសាសន៍របស់ក្រុមការងារចំពោះកិច្ច និងចាត់វិធានការឱ្យបានសមស្រប។

ផ្នែកទី ៧
ការដោះស្រាយវិវាទ

មាត្រា ២២
ការដោះស្រាយវិវាទដោយសន្តិវិធី

១. ភាគីណាមួយក៏ដោយអាចស្វែងរកការពិគ្រោះយោបល់ជាមួយភាគីណាមួយផ្សេងទៀត ឬភាគីនានាអំពីវិវាទណាមួយទាក់ទងទៅនឹងការបកស្រាយ ឬចំណុចណាមួយក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះជាមួយនឹងទស្សនៈ ដើម្បីឈានដល់ដំណោះស្រាយមួយដែលពេញចិត្តទាំងសងខាងបានឆាប់តាមដែលអាចធ្វើទៅបាន។

២. ក្នុងករណីដែលវិវាទមិនអាចដោះស្រាយបាន តាមរយៈការពិគ្រោះយោបល់ក្នុងអំឡុងពេលសមស្រប ភាគីទំនាស់ ត្រូវពិគ្រោះយោបល់រវាងពួកគេឱ្យបានឆាប់តាមដែលអាចធ្វើទៅបានជាមួយនឹងទស្សនៈឆ្ពោះទៅកាន់ការដោះស្រាយវិវាទ ដោយការចរចា ការស៊ើបអង្កេត ការសម្រុះសម្រួល ការផ្សះផ្សា ការដោះស្រាយមានអាជ្ញាកណ្ដាល ការដោះស្រាយដោយនីតិវិធីតុលាការ ឬតាមមធ្យោបាយសន្តិវិធីផ្សេងៗទៀតដែលជាជម្រើសរបស់ខ្លួន។

៣. វិវាទប្រភេទណាមួយដែលមិនអាចដោះស្រាយបាន ដោយមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ ការកាត់ក្ដីនឹងអាចត្រូវបានបញ្ជូនទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ តុលាការអន្តរជាតិស្ដីពីច្បាប់សមុទ្រ ឬអាជ្ញាកណ្ដាលដើម្បីដោះស្រាយ។ ក្នុងករណីទទួលបរាជ័យក្នុងកិច្ចព្រមព្រៀងលើការបញ្ជូនករណីវិវាទទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ តុលាការអន្តរជាតិស្ដីពីច្បាប់សមុទ្រ ឬទៅកាន់អាជ្ញាកណ្ដាល ភាគីទាំងឡាយត្រូវបន្តពិគ្រោះយោបល់ និងសហការដោយផ្អែកលើទស្សនៈដែលអាចឈានទៅដល់ការដោះស្រាយវិវាទ ដោយអនុលោមតាមច្បាប់អន្តរជាតិស្ដីពីការអភិរក្សធនធានមានជីវិតនៅក្នុងសមុទ្រ។

ផ្នែកទី ៨
ភាគីមិនមែនជាសមាជិក

មាត្រា ២៣
ភាគីមិនមែនជាសមាជិកនៃកិច្ចព្រមព្រៀងនេះ

១. ភាគីនៃកិច្ចព្រមព្រៀងទាំងអស់ ត្រូវលើកទឹកចិត្តដល់ភាគីមិនមែនជាសមាជិកឱ្យចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ ឬទទួលយកច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីមានវិធានការក្នុងការអនុវត្តស្របជាមួយនឹងបទប្បញ្ញត្តិរបស់ខ្លួន។

២. ភាគីនៃកិច្ចព្រមព្រៀងទាំងអស់ ត្រូវគោរពគ្នាទៅវិញទៅមក មិនរើសអើង និងមានតម្លាភាពស្របតាមកិច្ចព្រមព្រៀងនេះ និងច្បាប់អន្តរជាតិជាធរមាន ដើម្បីទប់ស្កាត់សកម្មភាពនានារបស់ភាគីមិនមែនជាសមាជិក ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងនេះ។

ផ្នែកទី ៩
ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ

មាត្រា ២៤
ការត្រួតពិនិត្យ ការពិនិត្យឡើងវិញ និងការវាយតម្លៃ

១. ភាគីទាំងឡាយ ត្រូវធានាបាននូវការត្រួតពិនិត្យជាទៀងទាត់ និងលក្ខណៈជាប្រព័ន្ធ និងពិនិត្យឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀងនេះ រួមទាំងការវាយតម្លៃពីភាពរីកចម្រើន ឆ្ពោះទៅរកការសម្រេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀង ដែលស្ថិតក្នុងក្របខណ្ឌរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ និងស្ថាប័នពាក់ព័ន្ធនានានៃអង្គការនេះ។

២. បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមានរយៈពេល៤ឆ្នាំ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិត្រូវរៀបចំកិច្ចប្រជុំជាមួយភាគីទាំងអស់ដើម្បីពិនិត្យឡើងវិញ និងវាយតម្លៃពីប្រសិទ្ធភាពនៃការសម្រេចបានតាមគោលបំណងរបស់កិច្ចព្រមព្រៀងនេះ។ ភាគីទាំងអស់ ត្រូវសម្រេចចិត្តថានឹងជួបប្រជុំគ្នាបន្តទៀតក្នុងករណីចាំបាច់។

ផ្នែកទី ១០
អវសានប្បញ្ញត្តិ

មាត្រា ២៥
ការចុះហត្ថលេខា

កិច្ចព្រមព្រៀងនេះ ត្រូវបានបើកសម្រាប់ការចុះហត្ថលេខានៅអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩ រហូតដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយប្រទេសទាំងអស់ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់។

មាត្រា ២៦
ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម

១. កិច្ចព្រមព្រៀងនេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមដោយហត្ថលេខី។

២. លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតម្កល់ទុកនៅកន្លែងអ្នកទទួលបន្ទុកតម្កល់ឯកសារ។

មាត្រា ២៧
ការចូលជាសមាជិក

១. បន្ទាប់ពីរយៈពេលបើកឱ្យចុះហត្ថលេខារួចមក ការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ពីសំណាក់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ណាមួយ នឹងនៅតែបើកចំហ។

២. លិខិតុបករណ៍នៃការចូលបន្ថែម ត្រូវតម្កល់នៅកន្លែងតម្កល់ឯកសារ។

មាត្រា ២៨
ការចូលរួមរបស់អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់

១. ដោយផ្អែកលើខ្លឹមសារដែលបានចែងក្នុងឧបសម្ព័ន្ធទី៩ មាត្រា ១ នៃអនុសញ្ញា ក្នុងករណីអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលជាអង្គការអន្តរជាតិ ដែលមិនមានសមត្ថកិច្ចគ្របដណ្តប់ទៅលើគ្រប់បញ្ហាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ឧបសម្ព័ន្ធទី៩ នៃអនុសញ្ញាត្រូវអនុវត្តនូវជម្រើសដូចគ្នា ដើម្បីឱ្យអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់បានចូលរួមក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែបទប្បញ្ញត្តិដូចខាងក្រោមមិនត្រូវបានអនុវត្តទេ៖

(ក) មាត្រា ២ វាក្យខណ្ឌទី១ និង

(ខ) មាត្រា ៣ កថាខណ្ឌទី១។

២. ដោយផ្អែកលើខ្លឹមសារដែលបានចែងក្នុងឧបសម្ព័ន្ធទី៩ មាត្រា ១ នៃអនុសញ្ញា ក្នុងករណីអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ដែលជាអង្គការអន្តរជាតិ មានសមត្ថកិច្ចទៅលើគ្រប់ចំណុចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិដូចខាងក្រោមនេះ ត្រូវអនុវត្តចំពោះការចូលរួមរបស់អង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ក្នុងកិច្ចព្រមព្រៀងនេះ៖

(ក) ក្នុងពេលចុះហត្ថលេខា ឬចូលសមាជិកបន្ថែម អង្គការទាំងនោះ ត្រូវធ្វើសេចក្តីប្រកាសដូចខាងក្រោមថា៖

(i) ខ្លួនមានសមត្ថកិច្ចទៅលើគ្រប់ចំណុចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ

(ii) ដោយហេតុផលថា ប្រទេសសមាជិករបស់ខ្លួនមិនអាចក្លាយជារដ្ឋភាគីបាន លើកលែងតែមានការគោរពដែនអធិបតេយ្យរបស់រដ្ឋទាំងនោះ ដែលអង្គការនេះគ្មានការទទួលខុសត្រូវឡើយ និង

(iii) ខ្លួនយល់ព្រមគោរពសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋនៃកិច្ចព្រមព្រៀងនេះ។

(ខ) ការចូលរួមរបស់អង្គការណាមួយបែបនេះ នឹងមិនមានករណីផ្ដល់សិទ្ធណាមួយក្នុងកិច្ចព្រមព្រៀងទៅលើរដ្ឋជាសមាជិកនៃអង្គការនេះ

(គ) ក្នុងករណីមានវិវាទរវាងកាតព្វកិច្ចរបស់អង្គការក្រោមកិច្ចព្រមព្រៀងនេះ និងកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងក្នុងការបង្កើតអង្គការ ឬសកម្មភាពណាមួយដែលពាក់ព័ន្ធកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវយកជាគោល។

មាត្រា ២៩
ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន៣០(សាមសិប)ថ្ងៃ ក្រោយពីថ្ងៃប្រគល់ឯកសារឱ្យអ្នកទទួលបន្ទុកតម្កល់ឯកសារនូវលិខិតុបករណ៍ទី២៥ (ម្ភៃប្រាំ) នៃការផ្ដល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលបន្ថែម អនុលោមទៅតាមមាត្រា ២៦ ឬមាត្រា ២៧។

២. សម្រាប់បណ្ដាប្រទេសហត្ថលេខីដែលផ្ដល់សច្ចាប័ន ទទួលយក ឬយល់ព្រមកិច្ចព្រមព្រៀងនេះ ក្រោយពីកិច្ចព្រមព្រៀងចូលជាធរមាន កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃតម្កល់លិខិតតុបករណ៍ នៃការផ្ដល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ។

៣. ចំពោះរដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ដែលឯកភាពយល់ព្រមតាមកិច្ចព្រមព្រៀងបន្ទាប់ពីចូលជាធរមាន កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីថ្ងៃដាក់តម្កល់លិខិតុបករណ៍នៃការចូលរួម។

៤. ក្នុងគោលបំណងនៃមាត្រានេះ លិខិតុបករណ៍ណាមួយដែលយកមកតម្កល់ដោយអង្គការសមាហ-រណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ មិនត្រូវបានរាប់បញ្ចូលជាឯកសារបន្ថែមដែលតម្កល់ទុកដោយរដ្ឋសមាជិកឡើយ។

មាត្រា ៣០
ការបម្រុងទុក និងការលើកលែង

គ្មានការបម្រុងទុក ឬការលើកលែង ត្រូវបានធ្វើឡើងក្នុងកិច្ចព្រមព្រៀងនេះឡើយ។

មាត្រា ៣១
សេចក្ដីប្រកាស និងសេចក្ដីថ្លែងការណ៍

មាត្រា ៣០ មិនបានរារាំងដល់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ពីការធ្វើសេចក្ដីប្រកាស ឬសេចក្ដីថ្លែងការណ៍ខណៈពេលចុះហត្ថលេខា ផ្ដល់សច្ចាប័ន ទទួលយក យល់ព្រម ឬការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ តែទោះជាយ៉ាងណាក៏ដោយ ការដាក់ឃ្លា ឬឈ្មោះជាមួយនឹងទស្សនៈ ជាអាទិ៍ ការធ្វើឱ្យមានស្តង់ដាររួមនៃច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនជាមួយនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ជាក់ពីការប្រកាស ឬសេចក្ដីថ្លែងការណ៍បែបនេះ ថាមិនមានបំណងដកចេញ ឬកែប្រែប្រសិទ្ធភាពស្របច្បាប់នៃបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ក្នុងការអនុវត្តកម្មវិធីរបស់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់នោះទេ។

មាត្រា ៣២
ការអនុវត្តបណ្ដោះអាសន្ន

១. កិច្ចព្រមព្រៀងនេះ នឹងត្រូវដាក់ឱ្យអនុវត្តជាបណ្ដោះអាសន្នដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ដែលយល់ព្រមទៅលើការអនុវត្តបណ្ដោះអាសន្នសម្រាប់អនុវត្តដោយជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកទទួលខុសត្រូវតម្កល់ឯកសារ។ ការអនុវត្តបណ្ដោះអាសន្ននេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃទទួលសេចក្ដីជូនដំណឹងនេះតទៅ។

២. ការអនុវត្តបណ្ដោះអាសន្នរបស់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ត្រូវបញ្ចប់ អាស្រ័យលើការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ សម្រាប់រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចថ្នាក់តំបន់ ឬអាស្រ័យលើសេចក្ដីជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកទទួលបន្ទុកតម្កល់ឯកសារ ដោយបញ្ជាក់ពីគោលបំណងនៃការបញ្ចប់ការអនុវត្តបណ្ដោះអាសន្នរបស់ខ្លួន។

មាត្រា ៣៣
វិសោធនកម្ម

១. រាល់ភាគីអាចស្នើធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះបាន បន្ទាប់ពីផុតសុពលភាពរយៈពេល២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

- រាយការណ៍អំពីសកម្មភាពនិងស្ថានភាពហិរញ្ញវត្ថុរបស់ **វ.គ.ស.ក.** ក្នុងរយៈពេលមួយឆ្នាំកន្លងមក
- រៀបចំបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិនីមួយៗ
- បោះឆ្នោតជ្រើសរើសសវនករសម្រាប់ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **វ.គ.ស.ក.**
- លើកសំណូមពរ ឬញត្តិទៅក្រុមប្រឹក្សាភិបាលនៃ **វ.គ.ស.ក.** ដែលត្រូវដោះស្រាយក្នុងរយៈពេល ៣ (បី) ខែ
- ពិនិត្យនិងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់ **វ.គ.ស.ក.**
- ពិគ្រោះយោបល់និងសម្រេចលើបញ្ហាផ្សេងៗទៀតដែលបានដាក់ស្នើដោយក្រុមប្រឹក្សាភិបាល។

មហាសន្និបាតវិសាមញ្ញអាចប្រជុំបាន លុះត្រាតែមានសមាជិកសកម្មដែលបានចុះបញ្ជីចំនួន ៣០% (សាមសិបភាគរយ) នៃសមាជិកសកម្មទាំងអស់ដែលបានចុះបញ្ជីដោយមានភ្ជាប់របៀបវារៈជាមួយផង យ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃប្រជុំ។

ផ្នែកទី ២
ក្រុមប្រឹក្សាភិបាលនៃ ទ.គ.ស.ក.

មាត្រា ៩.-

ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះមានសមាសភាព យ៉ាងច្រើន ១៩ (ដប់ប្រាំបួន) រូប រួមមានដូចខាងក្រោម ÷

- តំណាងសមាជិកសកម្មជាសវនករប្រតិស្រុត	៥រូប
- តំណាងសមាជិកសកម្មជាគណនេយ្យករជំនាញ	៣រូប
- តំណាងសមាជិកចូលរួម	២រូប
- តំណាងសមាជិកសមាគត	២រូប
- តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ	១រូប
- តំណាងស្ថាប័ននិយ័តករផ្សេងទៀត	មួយចំនួន
- តំណាងលេខាធិការដ្ឋាន **ទ.គ.ស.ក.**	១ រូប ជាលេខាធិការ។

សមាសភាពជាក់ស្តែងនៃក្រុមប្រឹក្សាភិបាលរបស់ **ទ.គ.ស.ក.** អាចត្រូវបានកំណត់និងកែសម្រួលយោងតាមការចាំបាច់នៃអាណត្តិនីមួយៗ។

មាត្រា ១០.-

ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធាន ១ (មួយ) រូបជាជំនួយការ។ ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសចេញពីសមាជិក **ទ.គ.ស.ក.** តាមរយៈនៃការបោះឆ្នោតនៅក្នុងមហាសន្និបាត លើកលែងតែសមាសភាពដែលជាតំណាងពីស្ថាប័នដូចបានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ។ ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ **ទ.គ.ស.ក.** ត្រូវបានតែងតាំងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ។

បេក្ខជនដែលអាចឈរឈ្មោះឱ្យគេបោះឆ្នោតធ្វើជាប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** បានលុះណាតែជាសមាជិកសកម្ម សមាជិកចូលរួម ឬសមាជិកសមាគត។

តំណាងពីស្ថាប័នផ្សេងៗ ជាសមាជិកក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ដោយស្វ័យប្រវត្តិតាមរយៈការចាត់តាំងពីស្ថាប័នសាមី។

ក្នុងករណីមិនមានតំណាងពីសមាជិកចូលរួម ឬសមាជិកសមាគតនៅក្នុងសមាសភាពក្រុមប្រឹក្សាភិបាល សមាជិកសកម្មត្រូវចូលមកបំពេញជំនួស។

សមាជិក **ទ.គ.ស.ក.** ដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ **ទ.គ.ស.ក.** បាន លុះណាតែជា សមាជិកសកម្ម សមាជិកចូលរួម និងសមាជិកសមាគត។

មាត្រា ១១.-

ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** មានមុខងារនិងភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ **ទ.គ.ស.ក.**
- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករនិងសវនករ
- ពិនិត្យនិងអនុម័តវិធានគ្រប់គ្រងនានារបស់ **ទ.គ.ស.ក.**
- ពិនិត្យនិងអនុម័តលើគោលនយោបាយ និងវិធានការនានាដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ **ទ.គ.ស.ក.**
- ពិនិត្យនិងអនុម័តលើផែនការយុទ្ធសាស្ត្រនិងគម្រោងថវិកាប្រចាំឆ្នាំដែលរៀបចំឡើងដោយលេខាធិការដ្ឋាននៃ **ទ.គ.ស.ក.**

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការថវិកាប្រចាំឆ្នាំរបស់ **ទ.គ.ស.ក.**
- ផ្តល់ការយល់ព្រមលើរបាយការណ៍លទ្ធផលការងារនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ទ.គ.ស.ក.**
- សម្រេចតែងតាំង ព្យួរការងារ និងបញ្ឈប់ការងាររបស់នាយកប្រតិបត្តិ និងកំណត់លាភការផ្សេងៗរបស់នាយកប្រតិបត្តិ
- សម្រេចលើគោលការណ៍ជ្រើសរើសបុគ្គលិករបស់លេខាធិការដ្ឋាននៃ **ទ.គ.ស.ក.**
- សម្រេចលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់លេខាធិការដ្ឋាននៃ **ទ.គ.ស.ក.**
- ពិនិត្យនិងសម្រេចលើការបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារនានា ស្របតាមតម្រូវការចាំបាច់របស់ **ទ.គ.ស.ក.**
- រាយការណ៍ជាលាយលក្ខណ៍អក្សរអំពីផែនការ គម្រោងថវិកា និងលទ្ធផលនៃការអនុវត្តផែនការ និងថវិកាមក **ក.ជ.គ.** និង
- ពិនិត្យនិងសម្រេចលើសំណើបើកការិយាល័យតំណាង និង/ឬសាខាតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ១២.-

អាណត្តិរបស់ក្រុមប្រឹក្សាភិបាលមានរយៈពេល ៤(បួន) ឆ្នាំ។ ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលដែលមកពី **ទ.គ.ស.ក.** អាចត្រូវបានបោះឆ្នោតជ្រើសតាំង និងតែងតាំងមិនឱ្យលើសពី ២ (ពីរ) អាណត្តិឡើយ។

មាត្រា ១៣.-

តួនាទីជាប្រធាន អនុប្រធាន ឬសមាជិកនៃក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** នឹងត្រូវបានបាត់បង់មុនពេលផុតអាណត្តិ ដោយមូលហេតុណាមួយដូចខាងក្រោម÷

- ការបាត់បង់សមាជិកភាពពី **ទ.គ.ស.ក.**
- ការលាលែងពីសមាជិកភាពដោយសាមីខ្លួនស្នើសុំ
- ការលាលែង ឬផ្លាស់ប្តូរប្រភេទសមាជិកភាពដើម
- ការបាត់បង់សមត្ថភាពការងារ
- ត្រូវបានផ្តន្ទាទោសតាមផ្លូវតុលាការ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- ការមិនចូលរួមប្រជុំចំនួន ៣ (បី) ដងជាប់ៗគ្នា ដោយគ្មានមូលហេតុសមស្រប
- មរណភាព។

សមាជិកក្រុមប្រឹក្សាភិបាលមកពី **ទ.គ.ស.ក.** ត្រូវបានបំពេញវិញដោយការបោះឆ្នោតតាមរយៈមហាសន្និបាតសាមញ្ញ សម្រាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិ។

មាត្រា ១៤.-

ក្នុងករណីប្រធានអវត្តមាន ដោយមូលហេតុមានជំងឺឬមិនអាចបំពេញការងារបានតទៅទៀត អនុប្រធាននៃក្រុមប្រឹក្សាភិបាលត្រូវធ្វើជាប្រធានស្តីទី រហូតដល់ប្រធានចូលបម្រើការងារវិញ។

មាត្រា ១៥.-

កិច្ចប្រជុំរបស់ ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** មាន ការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញ ។

មាត្រា ១៦.-

ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិច ៤ (បួន) ដង ក្នុងមួយឆ្នាំទៅតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់និងបន្ទាន់ ក្រុមប្រឹក្សាភិបាលអាចបើកការប្រជុំវិសាមញ្ញបានគ្រប់ពេលវេលាដើម្បីជាប្រយោជន៍ដល់វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា តាមសំណើរបស់ប្រធាន ឬតាមសំណើជាលាយលក្ខណ៍អក្សរ

របស់នាយកប្រតិបត្តិ ឬតាមសំណើពីសមាជិកនៃក្រុមប្រឹក្សាភិបាលចំនួនយ៉ាងតិច ៥០% (ហាសិបភាគរយ) នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

ក្នុងករណីប្រធានអវត្តមាន អនុប្រធាន ឬសមាជិកណាម្នាក់នៃក្រុមប្រឹក្សាភិបាលដែលមានអាយុច្រើនជាងគេត្រូវដឹកនាំការប្រជុំជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធាន។

របៀបវារៈនិងឯកសារនានាសម្រាប់កិច្ចប្រជុំសាមញ្ញត្រូវ ផ្ញើជូនគ្រប់សមាជិកក្រុមប្រឹក្សាភិបាលយ៉ាងតិច ៧(ប្រាំពីរ) ថ្ងៃ មុនថ្ងៃប្រជុំ។

មាត្រា ១៧.-

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅ បានលុះត្រាតែ មានវត្តមានសមាជិកលើសពី ៥០% (ហាសិបភាគរយ)នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។ សមាជិកអវត្តមាន មិនអាចបញ្ជូនតំណាងឱ្យមកប្រជុំជំនួសបានឡើយ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវមានការអនុម័តដោយសំឡេងភាគច្រើនដាច់ខាត នៃសមាជិកវត្តមាន។

មាត្រា ១៨.-

រាល់សេចក្តីសម្រេចនៃកិច្ចប្រជុំត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំនិងលេខាកត់ត្រានៃកិច្ចប្រជុំ។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាននិងសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាលក្នុងរយៈពេលយ៉ាងយូរ ១០(ដប់) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។

នាយកប្រតិបត្តិនៃលេខាធិការដ្ឋាននៃ **ទ.គ.ស.ត.** គឺជាលេខាធិការអចិន្ត្រៃយ៍នៃកិច្ចប្រជុំនានារបស់ **ទ.គ.ស.ត.**។

មាត្រា ១៩.-

ប្រធានក្រុមប្រឹក្សាភិបាលត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំអំពីការអភិវឌ្ឍ និងបញ្ហាប្រឈមនានាក្នុងវិស័យគណនេយ្យនិងសវនកម្ម និងរាយការណ៍អំពីផែនការ ការអនុវត្តសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាសនិងប្រចាំឆ្នាំជូនប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ។

មាត្រា ២០.-

ទ.គ.ស.ត. មាននិមិត្តសញ្ញា និងត្រាដោយឡែកក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

ផ្នែកទី ៣

គណៈកម្មការនៃ ទ.គ.ស.ត.

មាត្រា ២១.-

ទ.គ.ស.ត. មានគណៈកម្មការចំនួន ៤ (បួន) ជាសេនាធិការ ដូចខាងក្រោម÷

- គណៈកម្មការចុះឈ្មោះនិងសមាជិកភាព
- គណៈកម្មការបច្ចេកទេស
- គណៈកម្មការអប់រំ និងបណ្តុះបណ្តាល
- គណៈកម្មការស៊ើបអង្កេតនិងវិន័យ។

ទ.គ.ស.ត. អាចបង្កើតគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារនានា ស្របតាមតម្រូវការចាំបាច់របស់ខ្លួន។

គណៈកម្មការនីមួយៗដឹកនាំដោយប្រធាន ១ (មួយ) រូបនិងអនុប្រធាន ១ (មួយ) រូប ជាជំនួយការ។

អនុគណៈកម្មការនីមួយៗ និងក្រុមការងារនីមួយៗដឹកនាំដោយប្រធាន ១ (មួយ) រូប។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនីមួយៗ អនុគណៈកម្មការនិងក្រុមការងារនីមួយៗត្រូវសម្រេចនិងតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ត.**។

មាត្រា ២២.-

គណៈកម្មការចុះឈ្មោះនិងសមាជិកភាពមានភារកិច្ចដូចខាងក្រោម÷

- ពិនិត្យនិងសម្រេចលើលក្ខខណ្ឌតម្រូវនិងគុណវុឌ្ឍិសម្រាប់ចូលជាសមាជិករបស់ **ទ.គ.ស.ក.**
- ពិនិត្យនិងសម្រេចផ្តល់សមាជិកភាពដល់រូបវន្តបុគ្គល និង/ឬ នីតិបុគ្គលទាំងឡាយណាដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងសម្រេចលើការព្យួរ និងការដកហូតសមាជិកភាពនៃសមាជិករបស់ **ទ.គ.ស.ក.**
- ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះសមាជិករបស់ **ទ.គ.ស.ក.**
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ប្រគល់ជូន។

មាត្រា២៣.-

គណៈកម្មការបច្ចេកទេសមានភារកិច្ចដូចខាងក្រោម÷

- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលរៀបចំដោយក្រុមប្រឹក្សាជាតិគណនេយ្យ
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើសេចក្តីព្រាងស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាងដែលបានចេញផ្សាយដោយក្រុមប្រឹក្សាជាតិគណនេយ្យ ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ សហព័ន្ធគណនេយ្យករអន្តរជាតិ និងស្ថាប័នជាតិនិងអន្តរជាតិផ្សេងៗទៀត
- ផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសពាក់ពន្ធ័នឹងគណនេយ្យ សវនកម្ម និងការអះអាង ពន្ធដារ ក្រមសីលធម៌ អភិបាលកិច្ច និងការងារពាក់ព័ន្ធផ្សេងទៀត
- អនុវត្តភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ប្រគល់ជូន។

មាត្រា ២៤.-

គណៈកម្មការអប់រំនិងបណ្តុះបណ្តាលមានភារកិច្ចដូចខាងក្រោម÷

- រៀបចំនិងអនុវត្តតាមផែនការយុទ្ធសាស្ត្រនិងទិសដៅការងារដែលបានដាក់ចេញដោយគណៈកម្មាធិការជាតិគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- រៀបចំ អភិវឌ្ឍ និងគ្រប់គ្រងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀតស្របតាមតម្រូវការនិងការអភិវឌ្ឍនៃវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា
- រៀបចំ និងគ្រប់គ្រងការប្រឡងកម្មវិធីសិក្សាបច្ចេកទេសគណនេយ្យនិងកម្មវិធីសិក្សាផ្សេងៗទៀតរបស់ **ទ.គ.ស.ក.**
- អនុវត្តភារកិច្ចផ្សេងៗដែល ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ប្រគល់ជូន។

មាត្រា២៥.-

គណៈកម្មការស៊ើបអង្កេតនិងវិន័យមានភារកិច្ចដូចខាងក្រោម÷

- ទទួលនិងដោះស្រាយបណ្តឹងពីតតីយជនពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន
- បណ្តឹងឬវិវាទរវាងសមាជិកផងគ្នា
- ការមិនគោរពតាមក្រមសីលធម៌របស់សមាជិក
- ពិនិត្យ វាយតម្លៃនិងដាក់ពិន័យលើសមាជិកដែលបានប្រព្រឹត្តខុស និង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ប្រគល់ជូន។

ផ្នែកទី ៤
លេខាធិការដ្ឋាននៃ ទ.គ.ស.ក.

មាត្រា ២៦.-

ទ.គ.ស.ក. ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាលនិងបច្ចេកទេសអចិន្ត្រៃយ៍។ លេខាធិការដ្ឋានត្រូវដឹកនាំដោយនាយកប្រតិបត្តិ ១(មួយ)រូប ដែលត្រូវជ្រើសរើសនិងតែងតាំងដោយក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.**។

នាយកប្រតិបត្តិទទួលខុសត្រូវលើការគ្រប់គ្រងនិងសម្របសម្រួលកិច្ចការប្រតិបត្តិប្រចាំថ្ងៃរបស់ **ទ.គ.ស.ក.**។

មាត្រា ២៧.-

លេខាធិការដ្ឋាននៃ **ទ.គ.ស.ក.** មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំគ្រប់គ្រង និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ **ទ.គ.ស.ក.**
- រៀបចំកិច្ចប្រជុំរបស់ **ទ.គ.ស.ក.**
- រៀបចំនិងអនុវត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គម្រោងថវិកាប្រចាំឆ្នាំ និងផែនការនានា របស់ **ទ.គ.ស.ក.**
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងវិធាននានាសម្រាប់ការគ្រប់គ្រង **ទ.គ.ស.ក.**
- លើកសំណើសុំបើកការិយាល័យនៅតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- សហការយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានឧត្តមសិក្សាជាតិ និងអន្តរជាតិដើម្បីជំរុញការអនុវត្តកម្មវិធីសិក្សាគណនេយ្យស្របតាមបទដ្ឋានអន្តរជាតិ
- ធ្វើជាតំណាង **ទ.គ.ស.ក.** ក្នុងទំនាក់ទំនងជាមួយតតិយជន ដូចជា ស្ថាប័ននិយ័តករជាតិ ស្ថាប័នវិជ្ជាជីវៈគណនេយ្យក្នុងតំបន់ និងអន្តរជាតិដើម្បីលើកកម្ពស់និងការពារវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា
- រាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការអនុវត្តផែនការនិងថវិកាប្រចាំឆមាសនិងប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលរបស់ **ទ.គ.ស.ក.**
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.** ប្រគល់ជូន។

មាត្រា ២៨.-

ដំណើរការ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ **ទ.គ.ស.ក.**។

ជំពូកទី ៤
ប្រភេទសមាជិករបស់ ទ.គ.ស.ក.

មាត្រា ២៩.-

រូបវន្តបុគ្គលនិងនីតិបុគ្គលអាចប្រកបវិជ្ជាជីវៈផ្នែកគណនេយ្យ និង/ឬសវនកម្មបាន លុះត្រាតែបានចុះឈ្មោះជាសមាជិករបស់ **ទ.គ.ស.ក.**។

ប្រភេទនៃសមាជិករបស់ **ទ.គ.ស.ក.** មានដូចខាងក្រោម៖

- សមាជិកកិត្តិយស
- សមាជិកសកម្ម
- សមាជិកចូលរួម
- សមាជិកសមាគត
- សមាជិកបម្រុង ។

លក្ខខណ្ឌ និងគុណវុឌ្ឍិសម្រាប់ចុះឈ្មោះក្នុងប្រភេទសមាជិកនីមួយៗខាងលើត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.គ.ស.ក.**។

សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកនីមួយៗខាងលើត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.គ.ស.ក.**។

មាត្រា ៣០.-

សមាជិកកិត្តិយសអាចត្រូវបានផ្តល់ជាពិសេសដោយ **ទ.គ.ស.ក.** ជូនដល់សមាជិកដែលបានចុះឈ្មោះនៅក្នុងតារាងវិជ្ជាជីវៈអស់រយៈពេល ៣០ (សាមសិប) ឆ្នាំ យ៉ាងតិច ហើយបានឈប់ប្រកបវិជ្ជាជីវៈ។

សមាជិកកិត្តិយសក៏អាចត្រូវបានផ្តល់ជាពិសេសដោយ **ទ.គ.ស.ក.** ចំពោះបុគ្គលទាំងឡាយដែលបានបន្សល់ទុកគុណសម្បត្តិនិងស្នាដៃដ៏ឧត្តុង្គឧត្តមក្នុងការបម្រើ **ទ.គ.ស.ក.** ឬបានចូលរួមក្នុងការលើកស្ទួយនិងការអភិវឌ្ឍវិស័យគណនេយ្យនៅកម្ពុជា។

មាត្រា ៣១.-

សមាជិកសកម្មគឺជាគណនេយ្យករជំនាញ និងសវនករប្រតិស្រុតរបស់ **ទ.គ.ស.ក.** ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- សមាជិកសកម្មជា គណនេយ្យករជំនាញត្រូវមានសញ្ញាបត្រគណនេយ្យករជំនាញដែលទទួលស្គាល់ដោយ **ទ.គ.ស.ក.** មានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ពាក់ព័ន្ធនឹងវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម និងបំពេញរាល់លក្ខខណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង និងវិធានសមាជិកភាពរបស់ **ទ.គ.ស.ក.**។
- សមាជិកសកម្មជា **សវនករប្រតិស្រុត** ត្រូវមានសញ្ញាបត្រគណនេយ្យករជំនាញដែលទទួលស្គាល់ដោយ **ទ.គ.ស.ក.** មានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំពាក់ព័ន្ធនឹងវិជ្ជាជីវៈសវនកម្ម និងបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងនិងវិធានសមាជិកភាពរបស់ **ទ.គ.ស.ក.**។
- សមាជិកសកម្មអាចជារូបវន្តបុគ្គលឬនីតិបុគ្គលដែលស្ថិតនៅក្នុងឬប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។
- មានតែសមាជិកសកម្មទេដែលមានសិទ្ធិប្រកបវិជ្ជាជីវៈ ជាគណនេយ្យករជំនាញនិងសវនករប្រតិស្រុតដោយឯករាជ្យ។ សមាជិកសកម្មមានសិទ្ធិស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្ម ពីក្រុមប្រឹក្សាជាតិគណនេយ្យ។

មាត្រា ៣២.-

សមាជិកចូលរួមរបស់ **ទ.គ.ស.ក.** គឺជាបុគ្គលដែលបានបញ្ចប់កម្មវិធីសិក្សាគណនេយ្យករជំនាញជាតិ ឬមានសញ្ញាបត្រគណនេយ្យករជំនាញពីបរទេសដែលទទួលស្គាល់ដោយ **ទ.គ.ស.ក.**។

រូបវន្តបុគ្គលដែលជាថ្នាក់ដឹកនាំលើកិច្ចការគណនេយ្យ ឬហិរញ្ញវត្ថុតាមបណ្តាសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញអាចចុះឈ្មោះជាសមាជិកចូលរួមនៃ **ទ.គ.ស.ក.**។

រូបវន្តបុគ្គលដែលកំពុងបង្រៀនមុខវិជ្ជាគណនេយ្យ ហិរញ្ញវត្ថុ ឬសវនកម្ម នៅតាមគ្រឹះស្ថានសិក្សានានានៅក្នុងព្រះរាជាណាចក្រកម្ពុជាអាចចុះឈ្មោះជាសមាជិកចូលរួមនៃ **ទ.គ.ស.ក.**។

រូបវន្តបុគ្គលដែលកំពុងធ្វើការងារគណនេយ្យ ឬហិរញ្ញវត្ថុ នៅតាមស្ថាប័ននានា សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញអាចចុះឈ្មោះជាសមាជិកចូលរួមនៃ **ទ.គ.ស.ក.**។

មាត្រា ៣៣.-

សមាជិកសមាគតរបស់ **ទ.គ.ស.ក.** គឺជាបុគ្គលដែលមានសញ្ញាបត្រសាកលវិទ្យាល័យនិងដែលបានដាក់ពាក្យស្នើសុំ និងបានទទួលស្គាល់ឱ្យចូលជាសមាជិករបស់ **ទ.គ.ស.ក.**។

មាត្រា ៣៤.-

សមាជិកបម្រុងគឺជា បុគ្គលដែលកំពុងសិក្សាក្នុងកម្មវិធីគណនេយ្យករជំនាញជាតិ កម្មវិធីសិក្សាបច្ចេកទេសគណនេយ្យ និងកម្មវិធីសិក្សាគណនេយ្យជំនាញក្រោមកម្មវិធីប្រឡងរួមគ្នា ឬកម្មវិធីគណនេយ្យករជំនាញដទៃទៀតដែលទទួលស្គាល់ដោយ **ទ.គ.ស.ក.** ។

រូបវន្តបុគ្គលដែលកំពុងសិក្សាជំនាញគណនេយ្យ ឬហិរញ្ញវត្ថុ ឬ ពន្ធដារ នៅគ្រឹះស្ថានសិក្សានានាដែលទទួលស្គាល់ដោយ **ទ.គ.ស.ក.** អាចចុះឈ្មោះជាសមាជិកបម្រុងរបស់ **ទ.គ.ស.ក.**។

ជំពូកទី ៥
ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុនៃ វ.គ.ស.ក.

មាត្រា ៣៥.-

ប្រភពធនធាននិងថវិការបស់ **វ.គ.ស.ក.** បានមកពី៖

- វិភាគទានប្រចាំឆ្នាំរបស់សមាជិក
- កម្មវិធីបំប៉នសមត្ថភាពជំនាញដល់សមាជិកនិងសាធារណជន
- កិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិនានា
- អំណោយដោយផ្ទាល់និងដោយប្រយោលពីរាជរដ្ឋាភិបាលកម្ពុជា ស្ថានទូត ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គការសមាគមនានា
- ការបោះពុម្ពផ្សាយ និងកម្មវិធីឧបត្ថម្ភផ្សេងៗ
- មូលនិធិដែលបានមកពីការលក់សិទ្ធិនិពន្ធ ការបោះពុម្ពផ្សាយ និងពីការបើកវគ្គបណ្តុះបណ្តាល ការប្រជុំ និងការផ្សព្វផ្សាយ
- ចំណូលផ្សេងៗទៀត។

ប្រភពធនធាននិងថវិការបស់ **វ.គ.ស.ក.** ត្រូវប្រើប្រាស់ក្នុងគោលដៅបម្រើសកម្មភាពនានារបស់ **វ.គ.ស.ក.** និងមិនត្រូវបែងចែកជាភាគលាភក្នុងចំណោមសមាជិករបស់ខ្លួន ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងពីនេះឡើយ។

ការប្រើប្រាស់ធនធាននិងថវិកាទាំងនេះត្រូវស្ថិតនៅក្រោមអំណាចនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលរបស់ **វ.គ.ស.ក.**។

មាត្រា ៣៦.-

វ.គ.ស.ក. មានសិទ្ធិទទួលបាន និងគ្រប់គ្រង ជាកម្មសិទ្ធិករនូវចលនវត្ថុនិងអចលនវត្ថុ ជាអំណោយ ឬជាអច្ច័យទានរបស់ឯកជននិងអំណោយរបស់រដ្ឋ។

មាត្រា ៣៧.-

ការិយបរិច្ឆេទគណនេយ្យរបស់ **វ.គ.ស.ក.** ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ។ របាយការណ៍ហិរញ្ញវត្ថុត្រូវរៀបចំជារៀងរាល់ឆ្នាំ និងត្រូវដាក់ឱ្យធ្វើសវនកម្មដោយសវនករឯករាជ្យ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវរាយការណ៍ជូនសមាជិកនៅក្នុងមហាសន្និបាតប្រចាំឆ្នាំរបស់ **វ.គ.ស.ក.**។

ជំពូកទី ៦
អន្តរប្បញ្ញត្តិ

មាត្រា ៣៨.-

អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញនិងសវនករព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតត្រូវបន្តមានសុពលភាព រហូតដល់មានអនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធថ្មីមកជំនួសក្នុងក្របខ័ណ្ឌនៃការអនុវត្តអនុក្រឹត្យនេះ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

មាត្រា ៣៩.-

អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ត្រូវទុកជានិរាករណ៍និងត្រូវជំនួសទាំងស្រុងដោយអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ២ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២ ខែសីហា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨០៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា

សម្រេច

មាត្រា១. បំពាក់**មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា នៅតាមបណ្តាមូលដ្ឋានក្នុងខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម៖

ក-មេដាយ **មាសស្ថាបនាជាតិ**

១-ព្រះតេជគុណ	សៀក	សៅរឿន	បច្ច័យចំនួន ១០ ០០០ ដុល្លារ
២-ព្រះតេជគុណ	សួន	សារ៉េន	បច្ច័យចំនួន ១០ ០០០ ដុល្លារ
៣-ឯកឧត្តម	បែន	រ័ត្ន	ថវិកាចំនួន ៣០ ០០០ ដុល្លារ
៤-លោកជំទាវ	រ័ត្ន	សុខា	ថវិកាចំនួន ៣០ ០០០ ដុល្លារ
៥-ឯកឧត្តម	ម៉ុន	មាគ៌ា	ថវិកាចំនួន ៣០ ០០០ ដុល្លារ
៦-លោក	ប្រាក់	ប៊ុនណុន	ថវិកាចំនួន ៣០ ០០០ ដុល្លារ
៧-លោក	ហុង	ណាក់	ថវិកាចំនួន ៣០ ០០០ ដុល្លារ
៨-ឯកឧត្តម	ចាន់	សុវុឌ្ឍ	ថវិកាចំនួន ១០ ០០០ ដុល្លារ
៩-ឯកឧត្តម	សំ	សារិទ្ធ	ថវិកាចំនួន ១០ ០០០ ដុល្លារ
១០-ឯកឧត្តម	សំ	តុលា	ថវិកាចំនួន ១០ ០០០ ដុល្លារ
១១-ឯកឧត្តម	ហេង	បូរិន	ថវិកាចំនួន ១០ ០០០ ដុល្លារ
១២-ឯកឧត្តម	នី	ផល្លី	ថវិកាចំនួន ១០ ០០០ ដុល្លារ
១៣-ឧកញ៉ា	សុខ	ស្រស់	ថវិកាចំនួន ១០ ០០០ ដុល្លារ

១៤-លោកជំទាវ ធន ធូរ៉ែន ថវិកាចំនួន ១០ ០០០ ដុល្លារ
១៥-លោក ប្រាក់ សិទ្ធិសិលា ថវិកាចំនួន ១០ ០០០ ដុល្លារ
១៦-លោក យ៉ង ស៊ីថុល ថវិកាចំនួន ១០ ០០០ ដុល្លារ
១៧-លោក គឹម លន់ ថវិកាចំនួន ១០ ០០០ ដុល្លារ
១៨-លោក ខេង លន់ ថវិកាចំនួន ១០ ០០០ ដុល្លារ
១៩-លោក សួន គឹម ថវិកាចំនួន ១០ ០០០ ដុល្លារ
២០-លោក ឈឹម គឹមហុង ថវិកាចំនួន ១០ ០០០ ដុល្លារ
២១-លោក អ៊ាង ពិសិដ្ឋ ថវិកាចំនួន ១០ ០០០ ដុល្លារ
២២-លោក ឈាង ជ័រ ថវិកាចំនួន ១០ ០០០ ដុល្លារ
២៣-លោក ឡូយ សុផល ថវិកាចំនួន ១០ ០០០ ដុល្លារ
២៤-លោក រ៉ែន ប៉ា ថវិកាចំនួន ១០ ០០០ ដុល្លារ
២៥-លោក ជិន សាកែម ថវិកាចំនួន ១០ ០០០ ដុល្លារ
២៦-លោក សេង រស្មី ថវិកាចំនួន ១០ ០០០ ដុល្លារ
២៧-លោក ទេព សុវណ្ណ ថវិកាចំនួន ១០ ០០០ ដុល្លារ
២៨-លោក ធៅ វណ្ណា ថវិកាចំនួន ១០ ០០០ ដុល្លារ
២៩-លោក ឡុង សុភ័ក្រ្ត ថវិកាចំនួន ១០ ០០០ ដុល្លារ
៣០-លោក ប៊ិន គឹមស្រេង ថវិកាចំនួន ១០ ០០០ ដុល្លារ
៣១-លោក នូ និច ថវិកាចំនួន ១០ ០០០ ដុល្លារ
៣២-លោក អ៊ី សុផល ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៣-លោក អាំ ឌីណា ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៤-លោក ចាន់ សារឹម ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៥-លោក ស៊ឹម រ៉ាវី ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៦-លោក ជាម ដែន ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៧-លោក ថេង ធុន ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៨-លោក ម៉ែន ដេត ថវិកាចំនួន ១០ ០០០ ដុល្លារ
៣៩-លោក ឈន សុធន ថវិកាចំនួន ១០ ០០០ ដុល្លារ
៤០-លោក សួស ស៊ាងលី ថវិកាចំនួន ១០ ០០០ ដុល្លារ
៤១-លោក សាំ ហេង ថវិកាចំនួន ១០ ០០០ ដុល្លារ
៤២-លោក ហុង គឹមហឿន ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៣-លោក ប៉េង អេងហាក់ ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៤-លោក លឿង វឌ្ឍា ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៥-លោក អោម មុន្នីវណ្ណ ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៦-លោក ថាញ់ សុខវ៉ាត ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៧-លោក ផៃ វ៉ាន់ដា ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៨-អ្នកស្រី រ័ត្ន ពណ្ណារី ថវិកាចំនួន ១០ ០០០ ដុល្លារ
៤៩-លោក លី មន្នីរ៉ាត់ ថវិកាចំនួន ១០ ០០០ ដុល្លារ
៥០-លោក ស្រ៊ុន ផឹងឡាយ ថវិកាចំនួន ១០ ០០០ ដុល្លារ
៥១-លោក ខឿន ឧត្តមបញ្ញា ថវិកាចំនួន ១០ ០០០ ដុល្លារ

៥២-អ្នកស្រី	ឡាយ	សុធារី	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៣-លោក	អាន	វ៉េងស៊្រុន	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៤-លោក	ឡាយ	ឧត្តម	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៥-លោក	យូ	វ៉ិត្តចាន់សារ៉ា	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៦-លោក	មិន	សុវិសាល	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៧-លោក	គង់	វិចិត្រ	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៨-លោក	ស៊ិន	សំណាង	ថវិកាចំនួន ១០ ០០០ ដុល្លារ
៥៩-លោក	ម៉ិញ	សុភី	ថវិកាចំនួន ១០ ០០០ ដុល្លារ
៦០-លោក	ជួប	ការុណ	ថវិកាចំនួន ១០ ០០០ ដុល្លារ
៦១-លោក	ជាម	ពិសិដ្ឋ	ថវិកាចំនួន ១០ ០០០ ដុល្លារ

ខ-មេដាយ **ប្រាក់ស្ថាបនាជាតិ**

១-ព្រះតេជគុណ	ប្រេស	វីត	បច្ច័យចំនួន ៥ ០០០ ដុល្លារ
២-ឯកឧត្តម	សុខ	ខា	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣-ឧបាសិកា	វង្ស		ថវិកាចំនួន ៥ ០០០ ដុល្លារ
៤-លោក	យី	កួន	ថវិកាចំនួន ៥ ០០០ ដុល្លារ
៥-លោកអាចារ្យ	ថាន់	អ៊ើល	ថវិកាចំនួន ៥ ០០០ ដុល្លារ
៦-លោក	សាម	វ៉ាន	ថវិកាចំនួន ៥ ០០០ ដុល្លារ
៧-លោក	ប៊ុន	សុក	ថវិកាចំនួន ៥ ០០០ ដុល្លារ
៨-លោក	សៀក	សាក់	ថវិកាចំនួន ៥ ០០០ ដុល្លារ
៩-លោកអាចារ្យ	ជួន	ចាន់	ថវិកាចំនួន ៥ ០០០ ដុល្លារ
១០-អ្នកស្រី	សំ	ណាក់	ថវិកាចំនួន ៥ ០០០ ដុល្លារ
១១-អ្នកស្រី	សេង	លាភ	ថវិកាចំនួន ៥ ០០០ ដុល្លារ
១២-លោក	យឹម	ស៊ុនសូជា	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៣-លោក	យួន	អួន	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៤-ឧបាសក	ថៃ	ស៊្រុន	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៥-លោក	ហាក់	វុត្ថា	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៦-លោក	ម៉ៅ	សុខុន	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៧-លោក	ស៊ឹង	ចាន់អួន	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៨-លោក	អ៊ួច	សេរីវុទ្ធ	ថវិកាចំនួន ៥ ០០០ ដុល្លារ
១៩-លោក	ប្អូនសេង	សុពិសិដ្ឋ	ថវិកាចំនួន ៥ ០០០ ដុល្លារ
២០-លោក	ហួ	ជាវុធ	ថវិកាចំនួន ៥ ០០០ ដុល្លារ
២១-លោក	ហាក់	សុខសាធ	ថវិកាចំនួន ៥ ០០០ ដុល្លារ
២២-លោក	ខាប	វុធធឿន	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៣-លោក	គ្រី	ខេមរា	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៤-លោក	សែម	ពូន	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៥-លោក	ម៉ុក	សារ៉េន	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៦-លោក	ស៊ុំ	សែន	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៧-លោក	សុន	ពិសី	ថវិកាចំនួន ៥ ០០០ ដុល្លារ

២៨-លោក	ផៃ	សុខុន	ថវិកាចំនួន ៥ ០០០ ដុល្លារ
២៩-លោក	សែម	សុគន្ធា	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣០-លោក	គង់	សីហុង	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣១-លោក	ជាតិ	ម៉េងឡាយ	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣២-លោក	ប៉ុយ	ដាវី	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៣-លោក	ស	ទូច	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៤-លោក	កេត	សិរីរ័ត្ន	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៥-លោក	រឿន	សុជីវី	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៦-លោក	ហួត	វុធ	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៧-លោក	ជៀប	វិនដេ	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៨-លោក	រាជ	ជ្រិន	ថវិកាចំនួន ៥ ០០០ ដុល្លារ
៣៩-លោក	ទូ	វណ្ណឌី	ថវិកាចំនួន ៥ ០០០ ដុល្លារ
៤០-លោក	មុត	វុទ្ធី	ថវិកាចំនួន ៥ ០០០ ដុល្លារ
៤១-លោក	ឈាង	ម៉ាច	ថវិកាចំនួន ៥ ០០០ ដុល្លារ
៤២-លោក	សេត	សារី	ថវិកាចំនួន ៥ ០០០ ដុល្លារ
៤៣-លោក	ឃឹម	សារិន	ថវិកាចំនួន ៥ ០០០ ដុល្លារ
៤៤-លោក	គឹម	វណ្ណា	ថវិកាចំនួន ៥ ០០០ ដុល្លារ

ខ-មេដាយ**សំរឹទ្ធស្ថាបនាជាតិ**

១-លោក	សំ	វេង	ថវិកាចំនួន ៣ ០០០ ដុល្លារ
២-លោក	ប្លង់	សំអាន	ថវិកាចំនួន ៣ ០០០ ដុល្លារ
៣-លោកស្រី	យោន	ពិដោរ	ថវិកាចំនួន ៣ ០០០ ដុល្លារ
៤-លោក	លី	តៃឈន់	ថវិកាចំនួន ៣ ០០០ ដុល្លារ
៥-លោក	តាំង	តិចហ៊ាង	ថវិកាចំនួន ៣ ០០០ ដុល្លារ
៦-លោក	លី	ស៊ីវត្ថា	ថវិកាចំនួន ៣ ០០០ ដុល្លារ
៧-លោក	ណាំ	សុខអូន	ថវិកាចំនួន ៣ ០០០ ដុល្លារ
៨-លោក	ក្រាយ	ណារុំ	ថវិកាចំនួន ៣ ០០០ ដុល្លារ

មាត្រា២..រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានរដ្ឋសភា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ ពុធ ១០ កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨១០ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គលេខាធិការរដ្ឋសភា

សម្រេច

មាត្រា១.- បំពាក់**មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៧៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មាសការងារ**

១-លោកស្រី	ឈាង	សុភាព	មន្ត្រីរាជការ
២-លោក	សាន	ស៊ីម	មន្ត្រីរាជការ
៣-លោក	អ៊ូ	វល័ក្ខ	មន្ត្រីរាជការ
៤-លោក	កាន់	សុផាត	មន្ត្រីរាជការ
៥-លោក	ហ៊ឹម	គិរី	មន្ត្រីរាជការ
៦-លោកស្រី	សៅ	លីនដា	មន្ត្រីរាជការ
៧-លោក	ស៊ុំ	ប៉ា	មន្ត្រីរាជការ
៨-លោក	ឈុន	សឿង	មន្ត្រីរាជការ
៩-លោក	សៅ	ជួន	មន្ត្រីរាជការ
១០-លោក	ជិន	តុប	មន្ត្រីរាជការ

១១-លោក	ប៉ូ	សាន	មន្ត្រីរាជការ
១២-លោក	នូ	ឡូន	មន្ត្រីរាជការ
១៣-លោក	ណុប	អូន	មន្ត្រីរាជការ
១៤-លោកស្រី	គង់	ដានី	មន្ត្រីរាជការ
១៥-លោក	ផាន	សុម៉ៅ	មន្ត្រីរាជការ
១៦-លោក	ហន់	វេត	មន្ត្រីរាជការ
១៧-លោក	គៀក	ប៊ុនឡុង	មន្ត្រីរាជការ
១៨-លោក	ដុំ	ផាន	មន្ត្រីរាជការ
១៩-លោក	ផេង	សុខុន	មន្ត្រីរាជការ
២០-លោក	ញ៉ែម	នី	មន្ត្រីរាជការ
២១-លោក	លន់	សាមឿន	មន្ត្រីរាជការ
២២-លោក	ព្រំ	ម៉ុន	មន្ត្រីរាជការ
២៣-លោក	សួស	សន	មន្ត្រីរាជការ
២៤-លោក	មិន	ណាង	មន្ត្រីរាជការ
២៥-លោកស្រី	មាន	ដា	មន្ត្រីរាជការ
២៦-លោក	ជាម	ផល	មន្ត្រីរាជការ
២៧-លោក	ហួយ	នី	មន្ត្រីរាជការ
២៨-លោក	ស	ជីតា	មន្ត្រីរាជការ
២៩-លោក	ផាត	ផានិត	មន្ត្រីរាជការ
៣០-លោក	លន់	សុខគឿន	មន្ត្រីរាជការ
៣១-លោកស្រី	ចាន់	វណ្ណៈ	មន្ត្រីរាជការ
៣២-លោក	ស៊ាង	ឈុនលាក	មន្ត្រីរាជការ
៣៣-លោក	សោម	សួន	មន្ត្រីរាជការ
៣៤-លោក	អន	អ៊ាន	មន្ត្រីរាជការ
៣៥-លោក	នួន	សុន	មន្ត្រីរាជការ
៣៦-លោក	មាង	ថន	មន្ត្រីរាជការ
៣៧-លោក	ឡុង	សួយ	មន្ត្រីរាជការ
៣៨-លោក	មើក	ផ័ន្ទ	មន្ត្រីរាជការ
៣៩-លោក	គឹម	វាស្នា	មន្ត្រីរាជការ
៤០-លោក	សេន	សៅ	មន្ត្រីរាជការ

៤១-លោក	ហេង	សំណាង	មន្ត្រីរាជការ
៤២-លោក	លឹម	ទូច	មន្ត្រីរាជការ
៤៣-លោក	មាស	តុលា	មន្ត្រីរាជការ
៤៤-លោក	ចាន់	គីមស៊ាង	មន្ត្រីរាជការ
៤៥-លោក	គឹម	សុង	មន្ត្រីរាជការ
៤៦-លោក	ស្តើង	ស្រង់	មន្ត្រីរាជការ
៤៧-លោក	ញឿន	យូអេង	មន្ត្រីរាជការ
៤៨-លោក	ភិន	សួន	មន្ត្រីរាជការ
៤៩-លោក	ពៅ	ហឿន	មន្ត្រីរាជការ
៥០-លោក	ឈុន	ជា	មន្ត្រីរាជការ
៥១-លោកស្រី	ញ៉ាន	អូន	មន្ត្រីរាជការ
៥២-លោកស្រី	សោម	សាត	មន្ត្រីរាជការ

ខ-មេដាយ **ប្រាក់ការងារ**

១-លោកស្រី	ម៉េង	ចន្ធី	មន្ត្រីរាជការ
២-លោកស្រី	ឈីន	ស្រីលៃ	មន្ត្រីរាជការ
៣-លោកស្រី	ព្រៀម	សុគន្ធា	មន្ត្រីរាជការ
៤-លោក	អ៊ឹង	តុង	មន្ត្រីរាជការ
៥-លោក	ថូ	ចន្ធលី	មន្ត្រីរាជការ
៦-លោក	កក់	គាង	មន្ត្រីរាជការ
៧-លោកស្រី	ឌុន	ស្រីរី	មន្ត្រីរាជការ
៨-លោក	ហ៊ឹម	ដារ៉ែត	មន្ត្រីរាជការ
៩-លោក	ហ៊ិត	វង្សា	មន្ត្រីរាជការ
១០-លោក	ខឹម	សុខរ៉េន	មន្ត្រីរាជការ
១១-លោក	លាក់	ញឹន	មន្ត្រីរាជការ
១២-លោក	សែ	សុះ	មន្ត្រីរាជការ
១៣-លោក	ស្រស់	ស្រ៊ាន	មន្ត្រីរាជការ
១៤-លោក	ហោ	វណ្ណ	មន្ត្រីរាជការ
១៥-លោក	ងៀក	ហុងសេង	មន្ត្រីរាជការ
១៦-លោក	ឌី	គុជ	មន្ត្រីរាជការ
១៧-លោក	ប៊ាន	យឿង	មន្ត្រីរាជការ

១៨-លោក	ចេង	មុនី	មន្ត្រីរាជការ
១៩-លោក	ហម	សាវី	មន្ត្រីរាជការ
២០-លោក	សាន	សុវណ្ណកឿន	មន្ត្រីរាជការ
២១-លោក	ឱក	ញាណ	មន្ត្រីរាជការ
២២-លោក	ប៉ាវ	ឡុងឡឿន	មន្ត្រីរាជការ
២៣-លោក	ប៉ាង	ដាន	មន្ត្រីរាជការ
២៤-លោក	ខុន	ចន្ទី	មន្ត្រីរាជការ
២៥-លោក	ហាច	សេងហុង	មន្ត្រីរាជការ

មាត្រា២.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានរដ្ឋសភា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ ពុធ ១០ កើត ខែ ទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៨១១ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន **៥២ រូប** ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងធនធានទឹក និងឧតុនិយម ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៩** ដូចមានរាយនាមខាងក្រោម ៖

១- លោកជំទាវ **លឹម លីនដា** ពីវរមន្ត្រីថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

២- ឯកឧត្តម រុន តូ	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣- លោក តាំង សុផាត	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤- លោក ជុំ សិនិទ្ធ	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៥- លោកស្រី ឃុត សុខា	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៦- លោក ឈុន លីវ៉ាន់ដា	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៧- លោក ហាច ទីណោ	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៨- លោក ណុប វៀមណា	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៩- លោក ទូ កែតពុទ្ធរ័ត្ន	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១០- លោក ហ៊ី រិទ្ធី	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១១- លោក ទួន ត្រឹះស្លា	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១២- លោក កែច ច័យ	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៣- លោក ស៊ុន ជាវិទ្ធ	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៤- លោក ចែម ផល្លា	ពីវរមន្ត្រីថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៥- លោក អ៊ឹង តារារដ្ឋ	ពីវរមន្ត្រីថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៦- លោក ឈាន រតនា	ពីវរមន្ត្រីថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៧- លោក ទូ សុបិន	ពីវរមន្ត្រីថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៨- លោក អ៊ុច ភ្លឹង	ពីវរមន្ត្រីថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១៩- លោកស្រី គីម វ៉ានី	ពីវរមន្ត្រីថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
២០- លោក នាង សំអាត	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២១- លោកស្រី ជុំ ចាច	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២២- លោកស្រី ម៉េង ជាឧបធមរកត	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៣- លោកស្រី គង់ សុភា	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៤- លោក លឹម ជាទីជ	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៥- លោក មាស នរិន្ទ	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៦- លោក រ័ត្ន សុបិន	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៧- លោក សុខ សំសេរី	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៨- លោក សុខ សាមីល	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៩- លោក នេង វណ្ណា	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៣០- លោក ខ៉ែត សារី	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

៣១- លោក **ខែម សេរី**	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៣២- លោក **តូច ភិរុណា**	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៣៣- លោកស្រី **ជ័យ គឹមសានល័ក្ខស្មី**	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៣៤- លោក **យ៉ាន់ ប៊ុណ្ណា**	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
៣៥- លោក **ហុង គឹមសាន**	ពីវរមន្ត្រីថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

៣៦- លោក **ហ៊ីរ ច័ន្ទរស្មី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៣៧- លោក **ទ្រៀ រិទ្ធី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៣៨- លោកស្រី **ពៅ ផល្លា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៣៩- លោកស្រី **ប៊ិន ច័ន្ទមុនី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៤០- លោក **នង សុភាព** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៤១- លោក **ថោង ណាម៉ានី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ មកជាថ្នាក់លេខ ១

៤២- លោក **ប្រាក់ សាទី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៤៣- លោក **ឌិន សិរីរតនៈ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៤៤- លោក **សូ សំណាង** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៤៥- លោក **សុខ សារ៉ាត់** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកជាថ្នាក់លេខ ២

៤៦- លោក **សាន សុវិទ្យា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៤៧- លោកស្រី **ចាប រិទ្ធីនីតា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៤៨- លោក **ជា វណ្ណារ៉ា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៤៩- លោក **ម៉ាត់ វិសិដ្ឋ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៥០- លោក **ចាន់ ឡុង** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៥១- លោក **ជួន សុលីណា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

៥២- លោក **ញៀម ផល្លី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

មាត្រា ២ .- តម្លើងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ១៤ រូប ពីឋានន្តរស័ក្តិអនុមន្ត្រី មកជាឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងពីឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មកជាឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងនៅក្រសួងធនធានទឹក និងឧតុនិយម ចាប់ពីថ្ងៃទី ១៣ ខែ **មេសា** ឆ្នាំ **២០១៩** ដូចមានរាយនាមខាងក្រោម ៖

១- លោក **ម៉ៃ មិន** ពីអនុមន្ត្រីថ្នាក់លេខ ១ មកជាវរមន្ត្រីថ្នាក់លេខ ៤

២- លោក **ហ៊ឹម ផានីន** ពីអនុមន្ត្រីថ្នាក់លេខ ១ មកជាវរមន្ត្រីថ្នាក់លេខ ៤

៣- លោក **ខៃ ភារម្យ** ពីអនុមន្ត្រីថ្នាក់លេខ ១ មកជាវរមន្ត្រីថ្នាក់លេខ ៤

៤- លោកស្រី **សខ រតនា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៥- លោក **ណាំ ស៊ីឈន** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៦- លោក **ឃឿន សុខុម** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៧- លោកស្រី **ថេង ដានី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៨- លោក **សុខ អ៊ីសារ៉ា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

៩- លោក **ខាត់ ខេម៉ា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១០- លោក **ប៉េង សុធារៈ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១១- លោកស្រី **ផល្គុណា រតនា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១២- លោក **ណាំង ថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៣- លោក **ខាត់ សុខា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤- លោកស្រី **យ៉ាន់ សុខឿន** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៥ កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៨១២.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ៤៤ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី ១៣ ខែ **មេសា** ឆ្នាំ **២០១៩** ដូចមានរាយនាមខាងក្រោម ៖

១- លោក **លី សុភា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
២- លោកស្រី **ជា សុខនី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៣- លោក **ស្ងួន សទ្ធាឫទ្ធី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៤- ឯកឧត្តម **ទេស រុក្ខាផល**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៥- លោក **អុល ប៊ុនធឿន**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៦- លោក **ច័ន្ទ សុខុមចិត្តា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៧- លោក **ផេង ឈាងលី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៨- លោក **យ៉ូង ខេមរា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជា ថ្នាក់លេខ ១
៩- លោក **មឿន ហុក**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជា ថ្នាក់លេខ ២
១០- លោក **ជួប ណារ៉ាត់**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជា ថ្នាក់លេខ ២
១១- ឯកឧត្តម **សុខ សេដ្ឋា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជា ថ្នាក់លេខ ២
១២- លោក **សាម៉េន សុខា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៣- លោក **ហាច្យ អគ្គជារាស្សី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៤- លោក **ប៉ូល សុធារក្ស**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៥- លោក **គន់ សម្បត្តិ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៦- លោក **អ៊ួន សុទិច្ឆិភា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៧- លោក **តាំង ភាំង**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៨- លោក **ថៃ ហាឡា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
១៩- លោក **សុខ ម៉ិចវឌ្ឍនា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
២០- លោក **តេង នី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
២១- លោកស្រី **ខៀវ សុជាតិ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
២២- លោក **ខាត់ ម៉ុនសេង**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជា ថ្នាក់លេខ ៣
២៣- លោក **អ៊ិន ឫទ្ធី**	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៤- លោក **ឌុច ចាន់តូ**	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៥- លោក **វណ្ណា តារី**	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២៦- លោក **មាស ស៊ីចាន់**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៧- លោកស្រី **ឆន បុប្ផា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៨- លោក **គឹម វណ្ណារ៉ា**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៩- លោកស្រី **ស្រី ប៉ុណ្ណាជាទី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣០- លោក **សេក ច័ន្ទជាលី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៣១- លោក **ជុន ឫទ្ធី**	ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២

៣២- លោក **ម៉ម ពោន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៣- លោក **ស៊ិន វាសនា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៤- លោក **ឈួ ទិសេស** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៥- លោក **ហោ សុខសាយ** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៦- លោក **លឹម សៀងហួត** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៧- លោកស្រី **ភារប៉ុត សុមឡាប** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៨- លោក **ខាន់ រ៉ា** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៣៩- លោក **ឡូយ នុតសិទ្ធីសិទ្ធី** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៤០- លោក **កៅ ឡឿន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៤១- លោក **ទុំ ឋិត** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៤២- លោក **កែវ សុភារុន** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៤៣- លោក **ឡួន ឆេង** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣
៤៤- លោក **លឹម ស្រ៊ុនហ៊ាប** ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ មកជាថ្នាក់លេខ ៣

មាត្រា ២.- តម្លើងឋានន្តរស័ក្តិប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន **២៨** រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៩** ដូចមានរាយនាមខាងក្រោម៖

១- លោក **នេង សុវណ្ណវិសាល** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
២- លោក **ហែម សំអាត** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៣- លោកស្រី **ហួង សុភ័ក្រ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៤- លោក **គួយ វង្សសុរិន** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៥- លោក **ឌី សុខសិរី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៦- លោក **រស់ ចន្ថា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៧- លោក **ខន ពិសី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៨- ឯកឧត្តម **វង្ស សុវណ្ណ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
៩- លោក **លាង ប៉ោង** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១០- លោក **អ៊ាប សុវណ្ណា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១១- លោក **សុគន្ធ ពិជា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១២- លោក **ម៉ៅ អេងជី** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៣- លោក **ហឿន សុខណា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១
មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
១៤- លោក **លី រមេណី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៥- លោក **តុន សុភ័ក្ត** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤
១៦- លោក **សំ សុខ** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៧- លោក **ឆាយ សុខជា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៨- លោក **ហោង តុលា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

១៩- លោក **ឆាន់ ហោង** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២០- លោក **រុន រ័ត្នបូរ៉ា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២១- លោក **តុប ប៉ារី** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២២- លោក **ហុង មករា** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

២៣- លោក **ផន ផុន** ពីគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១
មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤

